មជ្ឈមណ្ឌលដើម្បី សន្តិភាព និង អភិវឌ្ឍន៍

វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា

Centre for Peace and Development (CPD)
Cambodia Development Resource Institute (CDRI)


# កំណត់ហេតុកិច្ចប្រជុំ ខប់សែលប្រ៉ម តំបន់ទី ២

# យន្តការបង្ការទំនាស់ក្នុងការបោះឆ្នោតនៅកម្ពុជា ដំណាក់កាលទី ២

ថ្ងៃព្រហស្បត្តិ៍ ទី១៦ ខែកុម្ភៈ ឆ្នាំ២០០៦

ខេត្តកណ្តាល

**ខប់សែល ដំណាក់កាលទី ២**

**COPCEL Phase II**


*ឧបត្ថម្ភដោយ / Sponsored by*

**កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ**

**United Nations Development Programme (UNDP)**

## របៀបវារៈនៃកិច្ចប្រជុំ

១. ចំណាប់អារម្មណ៍ស្វាគមន៍ ដោយលោក **ឡារី ស្ត្រេនូ (Larry Strange)** នាយកប្រតិបត្តិនៃវិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា (CDRI)

២. បទអន្តរាគមន៍ស្តីពីយន្តការ ឧប់សែលប្រ៉ុម (COPCELPROM) ដោយលោក **ឱក សេរី សោភក្តិ** ទីប្រឹក្សា និងជាអ្នកសំរបសំរួលយន្តការ ឧប់សែល នៃវិទ្យាស្ថាន CDRI

៣. ស្ថានភាពទូទៅ នៃការរៀបចំការបោះឆ្នោត ថ្លែងដោយលោក **គីម ហុង** ប្រធានគណៈកម្មាធិការរៀបចំការបោះឆ្នោត PEC ខេត្តកណ្តាល

៤. មតិរបស់អ្នកចូលរួមដែលបង្ហាញអំពីការប្រឈមទាំងឡាយក្នុងយន្តការរៀបចំការបោះឆ្នោតក្នុងបរិបទខេត្តកណ្តាល

៥. សេចក្តីផ្សេងៗ

## ១. ចំណាប់អារម្មណ៍ស្វាគមន៍ដោយលោក ឡារី ស្ត្រេនូ (Larry Strange) នាយកប្រតិបត្តិ នៃវិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា (CDRI)

លោក **ឡារី ស្ត្រេនូ** នាយកប្រតិបត្តិនៃវិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា CDRI មានប្រសាសន៍ថា ជាកិត្តិយសណាស់ដែលរូបលោកតំណាងវិទ្យាស្ថាន CDRI មកចូលរួម ឧប់សែលប្រ៉ុម នៅខេត្តកណ្តាលនេះ ។ តាងនាមវិទ្យាស្ថាន CDRI លោកបានសំដែងអំណរគុណដល់លោក គីម ហុង ប្រធានគណៈកម្មាធិការរៀបចំការបោះឆ្នោតខេត្ត (PEC) ឯកឧត្តម ឡៅ ស៊ុនប៉ា អភិបាលខេត្តកណ្តាលដែលបាន ជួយគាំទ្រដល់យន្តការ ឧប់សែលប្រ៉ុម របស់ក្រុមការងារឧប់សែល និងយុទ្ធនាការ ឧប់សែល របស់យើងខ្ញុំ ។ លោកក៏បានថ្លែងអំណរគុណផងដែរដល់ អស់លោក លោកស្រី ដែលជាតំណាងខាងស្ថាប័នរដ្ឋាភិបាល សង្គមស៊ីវិល គណបក្សនយោបាយទាំងអស់ដែលបានចូលរួមក្នុងវេទិកានេះ ។ លោកបានជំរាបជូនដោយខ្លីៗថា ហេតុអ្វីបានជាវិទ្យាស្ថាន CDRI យល់ថា ឧប់សែលប្រ៉ុម នេះមានសារៈសំខាន់ចំពោះការបោះឆ្នោតនៅកម្ពុជា ។

វិទ្យាស្ថាន CDRI ជាស្ថាប័នស្រាវជ្រាវឯករាជ្យមួយដែលធ្វើការស្រាវជ្រាវសំរាប់ជាគោលនយោបាយ ដល់ព្រះរដ្ឋាភិបាល និងស្រាវជ្រាវលើការអភិវឌ្ឍន៍ក្នុងប្រទេសកម្ពុជា ។ វិទ្យាស្ថាន CDRI ធ្វើការលើ វិស័យសំខាន់ៗជាច្រើន ដូចជា ការអភិវឌ្ឍន៍សេដ្ឋកិច្ច ពាណិជ្ជកម្ម ធនធានធម្មជាតិនិងបរិស្ថាន វិមជ្ឈការ កំណែទំរង់រដ្ឋបាល ជាពិសេសលើការងារ កសាងសន្តិភាព ។ ដើម្បីកំណត់ពីគុណភាពនៃការបោះឆ្នោតនានា និងដំណើរការអភិបាលកិច្ចប្រកបដោយប្រជាធិបតេយ្យ និងការបោះឆ្នោត ប្រកបដោយគុណភាព វិទ្យាស្ថាន CDRI ក៏បានបង្កើតយន្តការ ឧប់សែលនេះឡើងតាំងពី ៥ឆ្នាំមុន ។ ជោគជ័យនៃដំណាក់កាលទីមួយនៃយន្តការ ឧប់សែល របស់វិទ្យាស្ថានក្នុងប្រាំឆ្នាំដំបូង គឺបានដោយសារការប៉ិនប្រសព្វ និងសមត្ថភាពខ្ពស់របស់អ្នកសំរបសំរួលយើងខ្ញុំគឺ លោក ឱក សេរី សោភក្តិ ដែលនៅ តែបន្តការងារនេះ ។ លោក ឱក សេរី សោភក្តិ ក៏ដូចជាវិទ្យាស្ថាន CDRI បានឯកភាពគ្នាថា វប្បធម៌ពិភាក្សា គឺជួយសំរួលដល់ការកាត់បន្ថយទំនាស់ និងការមន្ទិលសង្ស័យគ្នាផ្សេងៗ ពិតជាមានសារៈសំខាន់ណាស់ ដូច្នេះ ឧប់សែល ព្យាយាមអញ្ជើញតួអង្គផ្សេងៗមកចូលរួម ដូចជាខាងរដ្ឋាភិបាល គណបក្សនយោបាយ សង្គមស៊ីវិល និងស្ថាប័នពាក់ព័ន្ធផ្សេងទៀត ដែលមានទឹកចិត្តចង់កសាងការបោះឆ្នោតមួយឱ្យបានល្អប្រសើរ ។ នៅពេល ដែលយើងរៀបចំតាក់តែងយន្តការ ឧប់សែល ដំណាក់កាលទី២ វិទ្យាស្ថាន CDRI យើងខ្ញុំបានចាប់អារម្មណ៍ថា ឧប់សែល គួរតែមានមួយនៅដំណាក់ កាលថ្នាក់ជាតិ និងមួយទៀតនៅថ្នាក់ខេត្ត ដែលយើងហៅថា ឧប់សែលប្រ៉ុម ។ វិទ្យាស្ថាន CDRI បានសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់ UNDP ដែលមើលឃើញពីសារៈសំខាន់នៃយន្តការនេះ មិនគ្រាន់តែអោយមាននៅថ្នាក់ជាតិទេ ព្រមទាំងគាំទ្រអោយមាននៅថ្នាក់ខេត្តទៀតផង ។

ជាទីបញ្ចប់លោក **ឡារី ស្ត្រេន្ទ** បានថ្លែងអំណរគុណដ៏ជ្រាលជ្រៅម្តងទៀត ដល់ឯកឧត្តមអភិបាលខេត្ត ប្រធានគណៈកម្មាធិការបោះឆ្នោតខេត្ត ចំពោះការជួយគាំទ្រ ក៏ដូចជាវត្តមានរបស់អស់លោក លោកស្រី នៅក្នុងពេលនេះ ហើយក៏សូមថ្លែងអំណរគុណដល់ លោកឌិក សេរី សោភក្តិ៍ ចំពោះការងារសំរបសំរួលរបស់លោក និងអស់លោក លោកស្រី ទាំងអស់ដែលបានចូលរួមនៅថ្ងៃនេះ ។

## ២. បទអន្តរាគមន៍ស្តីពីយន្តការ ខប់សែលប្រ៉ូម (COPCELPROM) ដោយលោក ឌិក សេរី សោភក្តិ៍ ទីប្រឹក្សា និងជាអ្នកសំរបសំរួលយន្តការ ខប់សែល នៃវិទ្យាស្ថាន CDRI

លោក **ឌិក សេរី សោភក្តិ៍** ទីប្រឹក្សាវិទ្យាស្ថាន CDRI និងជាអ្នកសំរបសំរួល កិច្ចប្រជុំខប់សែល បានស្វាគមន៍ដល់សមាជិកអង្គប្រជុំទាំងអស់ដែល បានចំណាយពេលអញ្ជើញចូលរួមក្នុងកិច្ចប្រជុំ ខប់សែលប្រ៉ូម ខេត្តកណ្តាលនេះ ជាពិសេសលោក គឹម ហុង អស់លោក លោកស្រី ប្រធានមន្ទីរប្រចាំខេត្ត តំណាងណបក្សធំៗទាំងបី និងសមាជិកក្រុមប្រឹក្សាឃុំសង្កាត់តំណាងអង្គការសង្គមស៊ីវិល ព្រះសង្ឃ លោកគ្រូ អ្នកគ្រូ។ លោកក៏សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់ ឯកឧត្តម អភិបាល ខេត្តកណ្តាល ដែលបានអនុញ្ញាតឱ្យក្រុមការងារ ខប់សែល មកជួបឯកឧត្តម និងសហការីទាំងអស់កាលពីប៉ុន្មានអាទិត្យមុននេះ ។ លោកក៏មាន ប្រសាសន៍ទាក់ទងនឹងជោគជ័យនៃខប់សែលប្រ៉ូម នៅខេត្តតាកែវ កំពត ក្រុងព្រះសីហនុ និងកំពង់ស្ពឺ ផងដែរ ។ ក្រោយពីកិច្ចប្រជុំ ខប់សែលប្រ៉ូម នៅខេត្តកណ្តាលនេះ ក្រុមការងារខប់សែល នឹងបន្តទៅរៀបចំនៅខេត្តមណ្ឌលគិរី ស្ទឹងត្រែង និងរតនៈគីរីទៀត រហូតដល់ ២៤ខេត្តក្រុង ហើយនឹងរៀបចំការប្រជុំឱ្យបានពីរដងក្នុងខេត្តនីមួយៗ រហូតដល់ឆ្នាំ២០០៨ ។

លោកក៏បានជំរាបប្រវត្តិខ្លីៗអំពីមូលដ្ឋាននៃការបង្កើតយន្តការខប់សែល នេះឡើងតាំងពី៥មុន ក្នុងឋានៈលោកជាអ្នកសំរបសំរួលកម្មវិធីសន្តិភាព និងការអភិវឌ្ឍន៍ នៅពេលនោះលោកបានធ្វើការស្រាវជ្រាវអំពីទំនាស់ដែលកើតមានឡើងនៅជុំវិញការបោះឆ្នោតឆ្នាំ១៩៩៨ និងបានរកឃើញ ប្រភពទំនាស់ច្រើន ជាពិសេសក្នុងការបោះឆ្នោតជាតិឆ្នាំ១៩៩៣ ដែលរៀបចំដោយអ៊ុនតាក់ និងការបោះឆ្នោតជាតិឆ្នាំ១៩៩៨ ដែលកម្ពុជាអ្នករៀបចំខ្លួនឯង ។

នៅពេលស្រាវជ្រាវ លោកបានស្រមៃនឹកឃើញដល់ការបង្កើតឡើងនូវយន្តការនេះ ។ ដូច្នេះតាំងពីឆ្នាំ១៩៩៩ ដល់ ២០០៣ ការប្រជុំទាំងអស់អត់មានអាក់ខានម្តងណាទេ យើងបានរៀបចំកិច្ចប្រជុំខប់សែល ថ្នាក់ជាតិចំនួន ៥០ដង មួយខែម្តង ដោយមានការគាំទ្រពី ក្រសួងមហាផ្ទៃ រាជរដ្ឋាភិបាល ហើយរាល់កំណត់ហេតុប្រជុំ គឺបានផ្ញើថ្វាយនិងជូនដល់ ព្រះមហាក្សត្រ សម្តេច ជា ស៊ីម សម្តេចក្រុមព្រះនរោត្តម រណឫទ្ធិ សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន ឯកឧត្តម សម រង្ស៊ី រដ្ឋមន្ត្រី និងមន្ត្រីពាក់ព័ន្ធ គ្រប់អង្គការ សង្គមស៊ីវិល ក្រុមអ្នកផ្តល់ជំនួយ និងឯកឧត្តម អភិបាលខេត្ត អភិបាលរង ខេត្ត-ក្រុង ព្រមទាំងគណបក្សនយោបាយនានា ។ នៅពេលដែលកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ (UNDP) បានឃើញថា យន្តការនេះ មានផលប្រយោជន៍ច្រើន ក្នុងការជួយ គជប ឱ្យរៀបចំការបោះឆ្នោតមួយដែលអាចទទួលស្គាល់បានពីមតិជាតិ និងអន្តរជាតិ UNDP បានទាក់ទងជាមួយ CDRI ហើយសុំឱ្យមានយន្តការនេះឡើងវិញ ។

គោលដៅដែលយើងបន្តធ្វើ យន្តការខប់សែលលើកទីពីរនេះ ជាពិសេសនៅថ្នាក់មូលដ្ឋាន ដែលយើងហៅថា ខប់សែលប្រ៉ូម (COPCELPRPOOM) មានដូចតទៅ: ***ទីមួយ*** គឺបញ្ហាអត្តសញ្ញាណប័ណ្ណ ដែលយើងគិតថា ប្រជាពលរដ្ឋខ្មែរត្រូវ ទទួលបានគ្រប់ៗគ្នា ។ សព្វថ្ងៃនេះ ប្រជាពលរដ្ឋ ប្រហែលជាជិត ៧លាននាក់ ក្នុងចំណោមប្រជាពលរដ្ឋ ប្រហែល ១៤.០០០.០០០ នាក់ ប្រជាពលរដ្ឋដែលដល់អាយុ ១៨ឆ្នាំ ដែលអាចទទួលអត្តសញ្ញាណប័ណ្ណបាន គឺមានចំនួន ៧.០០០.០០០នាក់ ហើយក្នុងនេះ ប្រជាពលរដ្ឋដែលបានទទួល អត្តសញ្ញាណប័ណ្ណមានតែជិត ៦.០០០.០០០ នាក់ទេ នៅសល់ជាង ១.០០០.០០០នាក់ទៀត ។ ក្នុងរឿង នេះយើងបានឆ្លងកាត់ ខេត្តច្រើនណាស់ ដែលយឺតយ៉ាវក្នុងការចេញអត្តសញ្ញាណប័ណ្ណ ហើយខេត្តខ្លះនៅមានបញ្ហាអវិជ្ជមាន ដោយមានការយកលុយ ដោយមន្ត្រី រឺ ភ្នាក់ងារដែលធ្វើ អត្តសញ្ញាណប័ណ្ណនោះ ។ យើងឃើញថា ដើម្បីឱ្យប្រជាពលរដ្ឋ ទៅបោះឆ្នោតបាន គឺមានតែសំរួលធ្វើយ៉ាងណា ឱ្យ ប្រជាពលរដ្ឋដល់អាយុ ១៨ឆ្នាំ មានអត្តសញ្ញាណប័ណ្ណគ្រប់ៗគ្នា ។ ប៉ុន្តែបញ្ហា

អត្តសញ្ញាណប័ណ្ណជាតិនេះ នៅតែជាបញ្ហានៅឡើយ ដែលយើងគិតថា នឹងធ្វើឱ្យបានក្នុងរយៈពេល ៣ឆ្នាំ ខាងមុខ ។ លោកបានជួបជាមួយ នឹងឯកឧត្តមអភិបាលខេត្តជាច្រើន ដែលបានសន្យាត្រៀមលក្ខណៈដើម្បី សហប្រត្តិបត្តិការជាមួយ ខប់សែល ដើម្បីធ្វើយ៉ាងណាឱ្យនៅក៏រិតឃុំ-ស្រុករបស់ឯកឧត្តម បានទទួលអត្តសញ្ញាណប័ណ្ណជាតិគ្រប់គ្នាព្រោះមាន តែឯកឧត្តមម្នាក់ទេ ដែលអាចចុះហត្ថលេខា លើអត្តសញ្ញាណប័ណ្ណបាន ។ ដូច្នេះឯកឧត្តមសន្យាថា អោយតែមកដល់ការិយាល័យឯកឧត្តម នឹង ចុះហត្ថលេខាឱ្យតែម្តង ហើយខាងនគរបាលលជាតិ វិញក៏ដូចគ្នាដែរ កម្មករកាត់ដេរដែលជាប់ធ្វើការជាមួយ នឹងក្រុមហ៊ុនចិន ។ បញ្ហាទាំងពីរនេះ ឯកឧត្តមបានសន្យាថា នឹង ដោះស្រាយ ឱ្យបានស្រួល មិនឱ្យបង្អែរបង្អង់ទៀតទេ បើសិនជាកន្លែងណាដែលមាន បញ្ហាអវិជ្ជមាន ដូចជា ការយកលុយកាក់ នឹងសុំឱ្យមានការប្តឹង ។ ឯកឧត្តម អភិបាលរង ខេត្តតាកែវបានសន្យានៅចំពោះមុខអង្គប្រជុំថា ពីថ្ងៃនេះ តទៅ នៅខេត្តតាកែវអត់មានបញ្ហា អវិជ្ជមានទាក់ទង នឹងអត្តសញ្ញាណប័ណ្ណនេះទៀតទេ បើមានករណីនេះ សូមជំរាបទៅលោកភ្លាម ។ ***ទីពីរ*** ចង់ឱ្យសំរេចបានក្នុង ៣ឆ្នាំខាងមុខនេះ គឺការសហការជាមួយ គជប និង PEC ធ្វើយ៉ាងណាឱ្យគោលដៅចុះឈ្មោះបោះឆ្នោតឱ្យបាន ១00% ។ យើងដឹងហើយថា នៅខេត្តកណ្តាលនេះ យើងទទួលបានលទ្ធផលល្អណាស់ជាង ៩0% ដែលយើងធ្វើចាប់ពីខែតុលាឆ្នាំមុន ហើយយើងនឹងខំប្រឹងធ្វើ យ៉ាងណាជំរុញឱ្យបានទៅដល់ ១00% តែម្តង ប្រជាពលរដ្ឋខ្មែរណាដែលមានអាយុ ១៨ឆ្នាំ មានសិទ្ធិបោះឆ្នោត ត្រូវបានទទួលអត្តសញ្ញាណប័ណ្ណ ហើយត្រូវមានឈ្មោះនៅក្នុងបញ្ជីឈ្មោះ អ្នកបោះឆ្នោត ។ យើងនឹងសហការជាមួយ គជប, PEC គណបក្សនយោបាយ អង្គការសង្គមស៊ីវិល ដើម្បីចលនាបជាពលរដ្ឋឱ្យប្រើប្រាស់ពេលវេលា នៃការចុះឈ្មោះត្រៀមនោះ យកប័ណ្ណដែលចុះឈ្មោះត្រៀម ទៅយកអត្តសញ្ញាណប័ណ្ណនោះ យើងធ្វើចលនាឱ្យប្រជាពលរដ្ឋ ឱ្យយកចិត្តទុកដាក់ ហើយចុះឈ្មោះឱ្យបានដល់គោលដៅ ១00% តែម្តង ។ យើងនឹងជួយសហប្រត្តិបត្តិការជាមួយ NEC នៅក្នុងរឿងនេះ ។ ***ទីបី*** ធ្វើយ៉ាងណាឱ្យយន្តការ ខប់សែល ប្រព្រឹត្តតាមមូលដ្ឋានទាំងអស់ នៅថ្នាក់ខេត្ត ក្រុង ស្រុក ឃុំ ឱ្យក្លាយទៅជាយន្តការមួយប្រកបទៅដោយ សន្តិសុខ គ្មានការភ័យខ្លាច គឺជាការបោះឆ្នោតដែលគ្មានអំពើហឹង្សា ដែលយើងអាច ទទួលស្គាល់ថា យើងបានឈានមកជា " ម្ចាស់ការ " លើយន្តការ បោះឆ្នោតដោយខ្លួនឯង ។ ប្រាកដហើយ នៅក្នុងការបោះឆ្នោតធំៗបែបនេះ យើងពិបាកនឹងធ្វើឱ្យបាន ១00% ណាស់ ទោះយ៉ាងណាក៏យើងនឹងធ្វើឱ្យ បាន ៩៨% ទៅ ៩៩% ។ ការណ៏នេះសំខាន់ណាស់ បើសិនជាយើងធ្វើបានមែន នោះនឹងមានការទទួលស្គាល់ពីមតិជាតិ និងអន្តរជាតិ ពិសេសមតិពីអ្នកផ្តល់ជំនួយ ដើម្បីឱ្យជំនួយ នៅតែបន្តហូរចូលមក ធ្វើការអភិវឌ្ឍន៍ប្រទេសជាតិយើង ដែលស្របតាមគោលនយោបាយចតុកោណរបស់ រាជរដ្ឋាភិបាល ក្នុងការកាត់បន្ថយភាព ក្រីក្រ ។ យន្តការខប់សែល ជួយក្នុងរឿងទាំងអស់នេះ ក្នុងគោលបំណងធ្វើយ៉ាងណាក្នុងរយៈពេល ៣ឆ្នាំខាង មុខនេះ ឱ្យបានសំរេចគោលដៅ ទាំងអស់នេះ ។ ***ទីបួន*** គឺចង់ឱ្យបានស្តាប់នូវប្រសាសន៍របស់លោក គឹម ហុងដែលជាប្រធាន PEC នឹងជំរាបជូនអំពីសភាពការបោះឆ្នោត និងការរៀបចំការបោះឆ្នោត នៅខេត្តកណ្តាលកន្លងមក ព្រមទាំងការរៀបចំការបោះឆ្នោតឃុំ-សង្កាត់ ឆ្នាំ២00៧ និងការបោះឆ្នោតថ្នាក់ជាតិឆ្នាំ ២00៨ ខាងមុខនេះ ។ តើមាន បញ្ហាណាខ្លះដែលយើងបានធ្វើរួច ហើយ បញ្ហាណាដែលកំពុងតែប្រឈម ដែលយើងគិតថា វាអាចក្លាយទៅជាឫស គល់មូលហេតុនៃទំនាស់នៅក្នុង រយៈពេល ៣ឆ្នាំខាងមុខនេះ ។

ជាពិសេស បងៗខាងក្រុមប្រឹក្សាឃុំ-សង្កាត់ ដែលមានវត្តមាននៅទីនេះ ដើម្បីមានប្រសាសន៏ថាតើនៅក៏រិតថ្នាក់ឃុំ មានបញ្ហាអ្វីខ្លះ ដែលជាបញ្ហាប្រឈមនៅសេសសល់កាលពីការបោះឆ្នោតក្រុមប្រឹក្សាឃុំ-សង្កាត់ នាឆ្នាំ២00២ និងបញ្ហាដែលសេសសល់ ពីការបោះឆ្នោតថ្នាក់ជាតិឆ្នាំ២00៣ ។ ប្រសាសន៍របស់បងៗក្រុមប្រឹក្សាឃុំ-សង្កាត់ អង្គការសង្គមស៊ីវិល និងស្ថាប័នពាក់ព័ន្ធទាំងអស់ ពិតជាមានសារៈសំខាន់ណាស់ ដើម្បីអោយយន្តការខប់សែលនេះ លើកស្ទួយវប្បធម៌នៃការជជែកពិភាក្សាគ្នាដោយត្រង់ទៅត្រង់មក វប្បធម៌នៃការជជែកពិភាក្សាគ្នាដោយដាក់បញ្ហានៅលើតុ មិននិយាយក្រោយខ្នងគ្នា ដើម្បីនឹងបង្ការទំនាស់ជាមួយគ្នា ដើម្បីឱ្យការបោះឆ្នោតនៅប្រទេសកម្ពុជាយើង ក្លាយទៅជាយន្តការមួយប្រកបដោយសន្តិភាព សេចក្តីសុខ សេចក្តីថ្លៃថ្នូរ ដែលជាមោទនភាពជាតិ ។

ដូចយើងបានឃើញស្រាប់ហើយថា ក្នុងរយៈពេលប៉ុន្មានអាទិត្យកន្លងមកនេះ យើងទាំងអស់គ្នាបានអបអរសាទរ ជាពិសេសអ្វីដែល សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន បានធ្វើការដឹកនាំប្រទេសកម្ពុជាឱ្យមានលំនឹង ទាំងស្ថិរភាពនយោបាយ និងសង្គម ដល់ប្រទេសជាតិយើង ហើយគួរជាទី

មោទនណាស់ដែលសម្តេច បានដោះស្រាយបញ្ហាដ៏ចាក់ស្រេះ ឱ្យបានធូរស្រាល ធ្វើឱ្យប្រជាពលរដ្ឋទាំងអស់កក់ក្តៅ អាចមានខួរក្បាលគិតដល់រឿងសេដ្ឋកិច្ច សង្គម និងការអភិវឌ្ឍន៍នៅក្នុងស្ថិរភាពសង្គមនយោបាយមួយដែលគួរឱ្យយើងមានមោទនភាពណាស់ នៅក្នុងរឿងនេះ ។

ដូច្នេះហើយបានជាយើងគិតថា ជំលោះ ឬទំនាស់ដែលមាននៅក្នុងយន្តការបោះឆ្នោតក្នុងប្រទេសកម្ពុជា សំរាប់រយៈពេល ៣ឆ្នាំខាងមុខនេះ ទំនាស់នោះអាចមាន ប៉ុន្តែមានជាពិសេសនៅថ្នាក់ក្រោម នៅថ្នាក់ដែលខាង PEC ហើយ CEC នោះត្រូវដោះស្រាយភ្លាមៗ ។ ដូច្នេះហើយបានជាយើងគិតថាការប្រជុំ ខប់សែល នៅថ្នាក់មូលដ្ឋាន សំខាន់ជាងនៅថ្នាក់ជាតិទៅទៀតនៅក្នុង ៣ឆ្នាំខាងមុខនេះ ។

ដោយទទួលបានការគាំទ្រពីអង្គការជាតិ និងអន្តរជាតិធំៗជាច្រើន ជាពិសេសខាង UNDP យន្តការ ខប់សែល បានទំនាក់ទំនងសហការជាមួយស្ថានីយ៍ទូរទស្សន៍ CTN ដើម្បីអោយមានការផ្សព្វផ្សាយតាមទូរទស្សន៍ ។ យើងនឹងទំនាក់ទំនងជាមួយវិទ្យុជាតិកម្ពុជា និងវិទ្យុរបស់ NGOs ដើម្បីផ្សព្វផ្សាយទៅដល់ប្រជាពលរដ្ឋទូទាំងព្រះរាជាណាចក្រកម្ពុជា ។ នៅថ្ងៃ ១៧នេះ លោក ឡារី ស្រ្តែន្ទ និងលោក នឹងបង្ហាញនៅតាមទូរទស្សន៍ CTN ម្តងទៀត ដើម្បីជំរាបជូនអំពី ខប់សែលប្រ៊ម នៅម៉ោង ៦:៣០នាទីព្រឹក យើងនឹងធ្វើការផ្សាយបន្តផ្ទាល់ថាតើខប់សែលប្រ៊មបានធ្វើអ្វីខ្លះនៅថ្នាក់ខេត្តទាំង ប៉ុន្មានដែលយើងបានឆ្លងកាត់រួចមកហើយ ។

## ៣. ស្ថានភាពទូទៅនៃការរៀបចំការបោះឆ្នោត ថ្លែងដោយលោក គឹម ហុង ប្រធានលេខាធិការដ្ឋានរៀបចំការបោះឆ្នោតខេត្តកណ្តាល

លោក គឹមហុង បានសំដែងការពេញចិត្តយ៉ាងខ្លាំងចំពោះយន្តការខប់សែល ហើយលោកតែងបានទទួលរបាយការណ៍យន្តការនេះច្រើនជាប្រចាំ តាំងតែពីខប់សែលដំណាក់កាល ទី១មក ដែលការប្រជុំនោះធ្វើឡើងតែនៅថ្នាក់ជាតិ ហើយលោកតែងតែនឹកចង់ឱ្យមានការប្រជុំបែបនេះនៅថ្នាក់ខេត្ត ឥឡូវនេះ បានមកដល់ខេត្តកណ្តាលដូចសេចក្តីប្រាថ្នាមែន ។ លោកពិតជាមោទនភាពណាស់ដែលវិទ្យាស្ថាន CDRI បានរៀបចំឱ្យមានការប្រជុំ ខប់សែលប្រ៊ប ថ្នាក់ខេត្តនេះ ជាឱកាសល្អណាស់ដើម្បីឱ្យតំណាងគណបក្សនយោបាយ ក៏ដូចជា អាជ្ញាធរគ្រប់លំដាប់ថ្នាក់ និងអ្នកអនុវត្តការងារផ្ទាល់នៅតាមក្រុមប្រឹក្សាឃុំ-សង្កាត់ បាន ជួបជុំគ្នា ដើម្បីសំដែងមតិ ។

លោកបានជំរាបជូនអង្គប្រជុំ អំពីស្ថានភាពទូទៅនៃការរៀបចំការបោះឆ្នោតនៅទូទាំងប្រទេសជាពីរចំណុចធំៗគឺ:

*១. ស្ថានភាពទូទៅនៃការងារបោះឆ្នោតទូទាំងប្រទេស*

បន្ទាប់ពីកិច្ចព្រមព្រៀងសន្តិភាពទីក្រុងបារីសថ្ងៃ២៣ តុលា ១៩៩១មក ប្រទេសកម្ពុជាបានដំណើរការរៀបចំការបោះឆ្នោតបាន ៥លើកដំបូងនៅក្នុងឆ្នាំ១៩៩៣ ដែលពេលនោះជាកាបោះឆ្នោតជ្រើសរើសសភាធម្មនុញ្ញ រៀបចំដោយអាជ្ញាធរបណ្តោះអាសន្ននៃអង្គការសហប្រជាជាតិហៅកាត់ថា អ៊ុនតាក់ ពេលនោះយើងឃើញថាគណបក្សដែលបានចូលរួមប្រកួតប្រជែងមាន ២០គណបក្ស សំរាប់អាសនៈ ១២០អាសនៈ ។ ប្រជាពលរដ្ឋដែលបានចុះឈ្មោះទៅបោះឆ្នោតនៅក្នុងឆ្នាំ១៩៩៣ មាន ៤.៧៦៤.៤៣០នាក់ ហើយបានទៅបោះឆ្នោតតែ ៤.២៦៧.១៩២នាក់ នេះជាស្ថិតិដំនើរការបោះឆ្នោតលើកដំបូងបំផុតនៅកម្ពុជា ។ គណបក្សដែលទទួលបានជ័យជំនះជាប់ឆ្នោតទទួលបានអាសនៈនៅក្នុងសភាធម្មនុញ្ញនោះ មានតែ ៤គណបក្សទេ គឺគណបក្សហ៊្វុនស៊ិនប៉ិច ៥៨អាសនៈ គណបក្សប្រជាជនកម្ពុជា ៥១អាសនៈ គណបក្សសេរីនិយមព្រះពុទ្ធសាសនា ១០អាសនៈ និងគណបក្សម៉ូលីណាការនិងអ្នកតស៊ូខ្មែរ ១អាសនៈ ។

បន្ទាប់មក នៅក្នុងឆ្នាំ១៩៩៨ គឺជាការបោះឆ្នោតជ្រើសតាំងអ្នកតំណាងរាស្រអាណត្តិទីពីរ ដែលរៀបចំឡើងដោយកម្ពុជាខ្លួនឯងផ្ទាល់ជាលើកដំបូង ដោយ គជប គ្រាន់តែមានការគាំទ្រ និងសហប្រតិបត្តិការពីសហគមន៍អន្តរជាតិផ្នែកថវិកា និងបច្ចេកទេសខ្លះប៉ុណ្ណោះ ។ នៅពេលនោះមានគណបក្សឈរឈ្មោះបោះឆ្នោត ៣៩គណបក្ស គឺកើនពី ២០ ដល់ ៣៩គណបក្ស សំរាប់ដណ្តើមយក ១២២អាសនៈ ។ ប្រជាពលរដ្ឋដែលបានទៅចុះឈ្មោះបោះឆ្នោត មាន ៥.៣៩៥.៥៩៥នាក់ ស្មើនឹង ៩៨,៣២% មិនបានទៅបោះឆ្នោតមាន ៥.០៥៧.៨៣០នាក់ ស្មើ ៩៣,៧៥% ។

យើងសង្កេតឃើញមានតែ ៣គណបក្សទេដែលជាប់ឆ្នោតក្នុងសភា គឺគណបក្សប្រជាជនកម្ពុជា ៦៤អាសនៈ គណបក្សហ៊្វុនស៊ិនប៉ិច ៤៣អាសនៈ និងគណបក្សសម រង្ស៊ី ១៥អាសនៈ ។

ឆ្នាំ២០០២ គឺជាការរៀបចំការបោះឆ្នោតជើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់ទូទាំងប្រទេសកម្ពុជា ដែលទាំងអស់មាន ១.៦២១ឃុំ-សង្កាត់ រៀបចំចាត់ចែងដោយផ្ទាល់ពី គជប ដោយមានការរួមចំណែកពីសហគមន៍អន្តរជាតិផងដែរ ។ គណបក្សដែលឈរឈ្មោះបោះ ឆ្នោតមាន ៨គណបក្ស ហើយប្រជាពលរដ្ឋដែលបានចុះឈ្មោះបោះឆ្នោតមាន ៥.១៩០.៣០៧នាក់ ស្មើនឹង ៨៣,០២% អ្នកដែលបានទៅបោះឆ្នោត មាន ៤.៥០៣.៩៧៤នាក់ ស្មើនឹង ៨៧,៥៥% ។ គណបក្សដែលទទួលបានអាសនៈក្នុងក្រុមប្រឹក្សាឃុំ-សង្កាត់ទូទាំងប្រទេស មាន ៤គណបក្សគឺ គណបក្សប្រជាជនកម្ពុជា ៧.៧០៣អាសនៈ គណបក្សហ៊្វុនស៊ិនប៉ិច ២.២១១អាសនៈ គណបក្ស សម រង្ស៊ី ១.៣៤៦អាសនៈ និងគណបក្សប្រជាធិបតេយ្យខ្មែរ ១អាសនៈ ។ សរុបសមាជិកក្រុមប្រឹក្សាឃុំ-សង្កាត់ទូទាំងប្រទេសកម្ពុជា មាន១១.២៦១ អាសនៈ។

ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រអាណត្តិទី៣ មាន ២៣គណបក្សចូលរួម សំរាប់យកអាសនៈ ១២៣អាសនៈ ។ ប្រជាពលរដ្ឋដែលបានចុះឈ្មោះបោះឆ្នោតចំនួន ៦.៣៤១.៨៣៤នាក់ ស្មើនឹង ៩៣,៩៥% អ្នកបានបោះឆ្នោតមាន ៥.២៧៧.៤៩៤នាក់ ស្មើនឹង ៨៣,២២% ។ ឯលទ្ធផលទទួលបាន គឺមាន ៣គណបក្ស គណបក្សប្រជាជនកម្ពុជា ៧៣អាសនៈ គណបក្សហ៊្វុនស៊ិនប៉ិច ២៦អាសនៈ គណបក្ស សម រង្ស៊ី ២៤អាសនៈ សរុបទៅ ១២៣អាសនៈ ។

កាលពីថ្ងៃទី ២២ មករា ឆ្នាំ២០០៦ គឺការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា នីតិកាលទី២ ដែលមានទ្រង់ទ្រាយតូចជាងការបោះឆ្នោត ៤លើកកន្លងមក ព្រោះថាអង្គបោះឆ្នោត និងអ្នកបោះឆ្នោត មានតែពីរ គឺសមាជិករដ្ឋសភា និងសមាជិកក្រុមប្រឹក្សាឃុំ-សង្កាត់ក្នុងតំណែង ។ គណបក្សនយោបាយចូលរួមឈរឈ្មោះបោះឆ្នោត មាន ៤គណបក្ស សំរាប់ប្រជែងយកអាសនៈ ៥៧អាសនៈ ។ លទ្ធផលទទួលបានគឺ គណបក្សប្រជាជនកម្ពុជា ៤៥អាសនៈ គណបក្សហ៊្វុនស៊ិនប៉ិច ១០អាសនៈ គណបក្ស សម រង្ស៊ី ២អាសនៈ ។ លើកនេះប្រើប្រាស់ថវិកាជាតិទាំងស្រុង ពុំមានជំនួយឧបត្ថម្ភពីប្រទេសណាឡើយ ។

លោកបានបញ្ជាក់ថា ក្នុងចំណោមការរៀបចំការបោះឆ្នោតទាំង៥ លើកនេះ គឺសុទ្ធតែជាការបោះឆ្នោតតាមប្រព័ន្ធសមាមាត្រទាំងអស់ ប៉ុន្តែមាន ៤លើក មានលក្ខណៈជាការបោះឆ្នោតបែបសាកល និង ១លើកចុងក្រោយ ជាការបោះឆ្នោតអសាកល ។

### *២. ស្ថានភាពទូទៅនៃការរៀបចំការបោះឆ្នោតរបស់ខេត្តកណ្តាល*

ការគ្រប់គ្រងការងាររដ្ឋបាលខេត្តកណ្តាលចែកចេញជា ១១ស្រុក ១៤៧ឃុំ និង១៨០៧ភូមិ ។ ការបោះឆ្នោតលើកដំបូងដែលរៀបចំដោយអ៊ុនតាក់ឆ្នាំ១៩៩៣ លោកពុំមានឯកសារគ្រប់គ្រាន់ទេ ។ ការបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រអាណត្តិទី២ ឆ្នាំ១៩៩៨ ខេត្តកណ្តាលមានប្រជាជនទាំងអស់ ១.០១៦.៤៥៧នាក់ ប្រជាពលរដ្ឋដែលគ្រប់អាយុ ១៨ឆ្នាំឡើងមាន ៥៣៧.៦៤៨នាក់ ប៉ុន្តែអ្នកដែលបានទៅចុះឈ្មោះឆ្នោតមានចំនួនច្រើនជាង ប្រហែលជាការធ្វើស្ថិតិច្រឡំយ៉ាងម៉េចទេ គឺមានដល់ ៥៣៨.២០៩នាក់ ចំនួនប្រជាពលរដ្ឋដែលបានទៅបោះឆ្នោតមាន ៥១៩.៦២៧នាក់ សំរាប់យកអាសនៈ ១១ ខេត្តកណ្តាលមាន ៣៦គណបក្សចូលរួម ។ លទ្ធផល គឺគណបក្សប្រជាជនកម្ពុជា ១៨៤.៧៤២សម្លេង ស្មើនឹង ៤អាសនៈ គណបក្សហ៊្វុនស៊ិនប៉ិចបាន ១៩៨.០៧៣សម្លេង ស្មើនឹង ៥អាសនៈ គណបក្សសម រង្ស៊ី ៨០.៨៨៥សម្លេង ស្មើនឹង ២អាសនៈ ។

ការបោះឆ្នោតឆ្នាំ២០០២ គឺការបោះឆ្នោតក្រុមប្រឹក្សាឃុំ-សង្កាត់ ខេត្តកណ្តាលមានប្រជាជនទាំងអស់ ១.១៣០.៣៩៣នាក់ អ្នកគ្រប់អាយុ ១៨ឆ្នាំឡើង មាន ៦២៦.៨៥២នាក់ អ្នកដែលបានចុះឈ្មោះបោះឆ្នោតមាន ៥៣១.៦៤៦នាក់ ស្មើនឹង ៨៤,៨១% អ្នកដែលបានទៅបោះឆ្នោតមាន ៤៨.៤៤៥៣នាក់ ស្មើនឹង ៩១,១៩% ចំនួនការិយាល័យបោះឆ្នោតឃុំមាន ១.១៦៨ការិយាល័យ ចំនួនក្រុមប្រឹក្សាឃុំទូទាំងខេត្តកណ្តាលដែលត្រូវជ្រើសរើសមាន ១.០៦១នាក់ គណបក្សនយោបាយចូលរួមចុះឈ្មោះប្រកួតមាន ៤គណបក្ស ។ លទ្ធផលគឺ គណបក្សប្រជាជនកម្ពុជា មានសម្លេងគាំទ្រ

៣៤.៦៥៧សម្លេង បានទទួលអាសនៈ ៧៥៤អាសនៈ, គណបក្សហ៊្វុនស៊ិនប៉ិច បានទទួលសម្លេងគាំទ្រ ៨២.៥៩៧សម្លេង បានអាសនៈ ១៦៥, គណបក្សសម រង្ស៊ី បានទទួលសម្លេងគាំទ្រ ៨៣.៩២៥សម្លេង ទទួលបានអាសនៈ ១៤២អាសនៈ ។

ការបោះឆ្នោត២០០៣ ជាការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រអាណត្តិទី៣ ខេត្តកណ្តាលមានប្រជាជនសរុប ១.១៤៤.២៨២នាក់ អ្នកដែលមានអាយុ ១៨ឆ្នាំឡើងលើ មាន ៦៦៦.៥៦៧នាក់ ចំនួនប្រជាពលរដ្ឋដែលបានទៅចុះឈ្មោះបោះឆ្នោតមាន ៦៣៦.៩៨២នាក់ ស្មើនឹង ៩៥.៥៥% ។ ឥឡូវលោក ឱក សេរី សោភក្តិ សំនូមពរឱ្យបាន ១០០% វាចេះតែកើតហើយ បន្តិចទៀតលោកនឹងធ្វើសុំនូមពរបន្ថែមលើបញ្ហានេះ ។ ប្រជាពលរដ្ឋដែលបានទៅបោះឆ្នោតមាន ៥៦៣.៤១៥នាក់ ស្មើនឹង ៨៨,៤៥% ចំនួនការិយាល័យបោះឆ្នោតមាន ១១៨០ការិយាល័យ កាលពីឆ្នាំមុនមាន ១.១៦៨ ឥឡូវឡើងដល់ ១.១៨០ការិយាល័យបោះឆ្នោត  គណបក្សនយោបាយដែលបានចូលរួមនៅខេត្តកណ្តាលមាន ១៩គណបក្ស សំរាប់ប្រជែងយកអាសនៈ ១១អាសនៈ លទ្ធផលសំរេចបាន គឺគណបក្សប្រជាជនកម្ពុជា បានទទួលសម្លេងគាំទ្រ ២២១.១៨៣សម្លេង ទទួលបាន ៥អាសនៈ គណបក្សហ៊្វុនស៊ិនប៉ិច បានទទួលសម្លេងគាំទ្រ ១៣៣.៧៥០សម្លេង បាន ៣អាសនៈ គណបក្សសម រង្ស៊ីបានទទួលសម្លេងគាំទ្រ ១៤២.៣១២សម្លេង បាន ៣អាសនៈ ។

ដោយឡែកការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភាថ្មី១ឆ្នាំ២០០៦នេះ គឺជាការបោះឆ្នោតអសាកល ដែលខេត្តកណ្តាលយើង ឋិតនៅក្នុងភូមិភាគទី ៣ ហើយអង្គបោះឆ្នោតដូចដែលជំរាបជូនមានតែពីរ គឺសមាជិករដ្ឋសភាក្នុងតំណែង និងសមាជិកក្រុមប្រឹក្សាឃុំនៅក្នុងតំណែង ដូច្នេះចំនួនសមាជិករដ្ឋសភានៅក្នុងតំណែងរបស់ខេត្តកណ្តាលមាន ១១រូប ចំនួនសមាជិក្រុមប្រឹក្សាឃុំនៅក្នុងតំណែង មាន ១.០៦១រូប សរុបទៅអ្នកដែលមានសិទ្ធិបោះឆ្នោតជ្រើសតាំងសមាជិកព្រឹសភាថ្មី១នេះ មាន១០៧២រូប ។ ការិយាល័យមានតែពីរទេ គឺមជ្ឈមណ្ឌលគរុកោសល្យភូមិភាគហ៊ុន សែន ខេត្តកណ្តាលមួយ និងនៅខាងក្រៅមួយ ទៀត ហើយលទ្ធផលចុងក្រោយ គឺគណបក្សប្រជាជនកម្ពុជា ទទួលបានសម្លេងគាំទ្រ ៧៥៨សម្លេង ទទួលបាន ៤អាសនៈ, គណបក្សហ៊្វុនស៊ិនប៉ិច ទទួលបាន ១៦៦សម្លេង ទទួលបាន ១អាសនៈ, គណបក្សសម រង្ស៊ីទទួលបាន ១៣៦សម្លេង បានសូន្យអាសនៈ ។

លោកបានជំរាបជូនអង្គប្រជុំអំពីការចុះឈ្មោះដែលពាក្យបច្ចេកទេសហៅថា ការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតប្រចាំឆ្នាំថា ជារៀងរាល់ឆ្នាំទោះបីមានការបោះឆ្នោតក្តី មិនមានការបោះឆ្នោតក្តី ក៏ គជប តែងតែឱ្យមានការចុះឈ្មោះជាប្រចាំឆ្នាំបណ្តើរ១ ដើម្បីត្រៀមទុកសំរាប់ការបោះឆ្នោតលើកក្រោយ១ ដែលលោក ឱក សេរី សោភក្តិ មានប្រសាសន៍ច្បាស់លាស់អំពីយន្តការនៃការចុះឈ្មោះនេះ គឺធ្វើឱ្យបាន ១០០% ។ ដូច្នេះមុននឹងចូលដល់រឿងនេះ ដោយមានវត្តមាន អស់លោកជាអភិបាល អភិបាលរងគ្រប់ស្រុក ប្រធានក្រុមប្រឹក្សាឃុំ-សង្កាត់ តំណាងគណបក្សនយោបាយ គឺលោកសូមសំនូមពរជួយជំរុញបញ្ហានេះផង ។ លោកបានសំណូមពរដល់ប្រធានក្រុមប្រឹក្សាឃុំ-សង្កាត់ទាំងអស់ ពេលត្រឡប់ទៅវិញសូមប្រជុំជាមួយក្រុមប្រឹក្សាឃុំ ក៏ដូចជាស្មៀនឃុំ ឱ្យជំរុញដំណើរការនៃការចុះឈ្មោះត្រៀមនេះឱ្យបានពីឥឡូវជាបណ្តើរ១ ។

លោកជំរាបជូនផងដែរពីការចុះឈ្មោះប្រចាំឆ្នាំ២០០៤ ការចុះឈ្មោះប្រចាំឆ្នាំ២០០៤កន្លងមកនេះ ក៏ទទួលបានលទ្ធផលជាគួរ ឱ្យពេញចិត្តដែរ ប៉ុន្តែគ្រាន់តែជាការចុះឈ្មោះប្រចាំឆ្នាំលើកទីមួយ នៅជួបការលំបាកផ្នែកបច្ចេកទេសខ្លះ ប៉ុន្តែឥឡូវ យើងបានឆ្លងកាត់ ៣ដងហើយ ចំណែកការចំណាយថវិកាវិញ ក៏មានការថយចុះដែរ។ ប្រជាពលរដ្ឋសរុបរបស់ខេត្តកណ្តាលយើងមាន ១.១៧៤.៦៧៣នាក់ ប្រជាពលរដ្ឋមានអាយុ ១៨ឆ្នាំ មាន ៦៩១.០៩៧នាក់ អ្នកដែលបានចុះឈ្មោះថ្មី (យើងមិននិយាយចុះឈ្មោះទាំងអស់ទេ គឺចុះឈ្មោះថ្មីសំរាប់អ្នកដែលមិនបានចុះ អ្នកផ្លាស់ចូលពីឃុំមួយទៅឃុំមួយ ទើបមានប្តីប្រពន្ធ) មាន ២៤.៩២៣នាក់ ហើយយើងលុបឈ្មោះចេញពីបញ្ជីសំរាប់អ្នកស្លាប់ អ្នកខុសលក្ខណៈវិនិច្ឆ័យមាន ៥.៧៣៨នាក់ អ្នកផ្លាស់ចេញជាដើម ។

លោកក៏បានជំរាបជូនពីការចុះឈ្មោះ និងការពិនិត្យបញ្ជីឈ្មោះបោះឆ្នោតប្រចាំឆ្នាំ២០០៥ ដែលបានធ្វើរួច ហើយខេត្តកណ្តាលមានប្រជាពលរដ្ឋ សរុបកើនជិត ២លាននាក់ ហើយប្រជាពលរដ្ឋអាយុ ១៨ឆ្នាំឡើងគឺ ៦៩៧.០០៥នាក់ អ្នកបានចុះឈ្មោះថ្មីមាន ២១.៦៦៤នាក់ ហើយលុប

ឈ្មោះចេញ ពីបញ្ជីបាន ៤.២៨៤នាក់ ។ សរុបអ្នកមានឈ្មោះក្នុងបញ្ជីបោះឆ្នោតសំរាប់ឆ្នាំ២០០៥ មាន ៦៧៣.៤០៤នាក់ ស្មើនឹង ៩៦.៦១% ។ ឯការិយាល័យ បោះឆ្នោតដែលយើងត្រៀមកើនពី ១.២៤៩ មកដល់ ១.២៦៩ការិយាល័យ ហើយនេះជាស្ថិតិដែលយើងបានចុះឈ្មោះប្រចាំឆ្នាំ ហើយសង្ឃឹមថា ការចុះឈ្មោះបោះឆ្នោតសំរាប់ឆ្នាំ២០០៦នេះ អាចបានតាមសំនូមពររបស់ ឧប់សែល ។ ក្នុងការងារបោះឆ្នោត យើងចែកជាដំណាក់៧ទៅ យើងអាចកត់សំគាល់ឃើញថា មាន ៤ ឬ ៥ដំណាក់កាលគឺ:

**ដំណាក់កាលទីមួយ** ជាដំណាក់កាលចុះឈ្មោះ ការចុះឈ្មោះនេះចេះតែវិវឌ្ឍន៍ ហើយបើធៀបនឹងសម័យអ៊ុនតាក់ឆ្នាំ១៩៩៣ ការចុះឈ្មោះមិនប្រកាន់ទីលំនៅទេ អ្នកណាចង់ទៅចុះកន្លែងណាក៏បានដែរ ហើយគេឱ្យប័ណ្ណនោះមក គឺចប់ ។ ប៉ុន្តែ គជប យើងមាននីតិវិធីត្រឹមត្រូវ គឺអ្នកមានទីលំនៅកន្លែងណា យើងចុះឈ្មោះកន្លែងនោះ ហើយអ្នកដែលចុះឈ្មោះគេហៅថា មន្ត្រីចុះឈ្មោះបោះឆ្នោត ឬភាសាអង់គ្លេសហៅថា RSO ក្រោមការគ្រប់គ្រងរបស់មន្ត្រីរៀបចំការបោះឆ្នោតថ្នាក់ឃុំ ដែលយើងហៅថា CEC ។ CEC នេះគ្រប់គ្រង RSO ហើយ RSO ទទួលបន្ទុកភារកិច្ចចុះឈ្មោះឱ្យប្រជាពលរដ្ឋនៅក្នុងឃុំរបស់ខ្លួន ហើយចំនួន RSO មួយក្រុមមាន ៦នាក់ ទទួលបន្ទុក តែ ៤-៥ការិយាល័យប៉ុណ្ណោះ ហើយមានម្នាក់សំរាប់តែថត ។ បើឃុំណាមានចំនួនប្រជាជនច្រើនលើសពី ៧-៨ការិយាល័យ គេឱ្យមានពីរក្រុម RSO ឃុំណាធំមានដល់ទៅជាង ១០ការិយាល័យបោះឆ្នោតគឺ ២០ជាង ដូចជាស្រែអំបិល នៅស្រុកស្អាង ឃុំតាខ្មៅ ស្រុកតាខ្មៅ និងឃុំក្បាលកោះ ស្រុកកៀនស្វាយ នោះសុទ្ធតែមាន PSO ៣ ឡើងលើ ដូច្នេះអ្នកដែលចុះឈ្មោះ គឺមន្ត្រីបោះឆ្នោតក្រោមការគ្រប់គ្រងរបស់ PEC ដែរ ។

ចាប់ពីឆ្នាំ១៩៩៨ ដល់ឆ្នាំ២០០២ យើងចុះឈ្មោះដូចគ្នា គឺមន្ត្រីចុះឈ្មោះបោះឆ្នោតឱ្យប្រជាជននៅតាមឃុំ ក្រោមការគ្រប់គ្រងរបស់ PEC ដោយឡែកនៅឆ្នាំ២០០៣ ដែលជាឆ្នាំបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រអាណត្តិទី៣ គជប ហើយក្រសួងមហាផ្ទៃ បានធ្វើប្រតិភូកម្មអំណាចឱ្យក្រុមប្រឹក្សា ឃុំ ជាអ្នកទទួលបន្ទុកចុះឈ្មោះ ជាពិសេសស្មៀន ជាអ្នកអនុវត្តន៏ការងារនេះ ។

**ដំណាក់កាលទីពីរ** គឺការចុះបញ្ជីគណបក្សនយោបាយ បញ្ហានេះមិនបាច់និយាយច្រើនទេ គណបក្សនយោបាយលោកសុទ្ធតែត្រៀមខ្លួនអស់ហើយ លោកត្រៀមហើយថាគួរចូលប្រកួត ឬមិនចូល ។ តើនរណាខ្លះដែលត្រូវដាក់ជាបេក្ខជន ព្រោះជាការបោះឆ្នោតបែបសមាមាត្រ តើនរណាដាក់ជាបេក្ខជន មិនពិបាកទេ ។ ទោះយ៉ាងណា នៅមានបញ្ហា ខ្លះដែរកន្លងមក ដូចជាការបោះឆ្នោតឃុំ គឺបញ្ហាទំនាស់លេខរៀង ដណ្តើមលេខរៀងគ្នា នៅពេលមានការប្រទាញប្រទង់លេខរៀងគ្នាធ្វើឱ្យការ ដាក់បញ្ជីឈរឈ្មោះបេក្ខជនយឺតរហូតដល់ផុតកំណត់ ក៏មានដែរ ។ ការងារបោះឆ្នោតមានរយៈពេលកំណត់ណាស់ច្បាស់ណាស់ ហើយមិន ត្រឹមកំណត់ត្រឹមតែថ្ងៃទេ កំណត់ម៉ោងទៀត ។ ឆ្នាំមុន៧មានបញ្ហា លេខរៀងអ្នកនេះលើ ដាក់អ្នកនេះក្រោម ជួនកាលហួសម៉ោង តាំងមានការប្តឹង នៅខេត្តកណ្តាលយើង ធ្លាប់ជួបបញ្ហានេះ ។

**តំណាក់កាលទីបី** យុទ្ធនាការឃោសនារកសម្លេងគាំទ្រ

នេះជាដំណាក់កាលដែលក្តៅ កន្លងមកគណបក្សនយោបាយខ្លះ ដូចជាមិនសូវគោរពតាមក្រមសីលធម៌នៃគណបក្ស ឬនីតិវិធីនៃការងារបោះឆ្នោត គាត់មិនបានជំរាបមក PEC ជួនកាលការដង្ហែរក្បួន ជាន់កម្មវិធីគ្នា ហើយចង់បានកន្លែងដូចគ្នា ហើយប្រើពាក្យសំដីជេរ្មដងម គ្រោតគ្រាតអាចឱ្យមានការប៉ះទង្គិចឱ្យមានការប្តឹង PEC ។ ដូចច្នេះលោកបានសំណូមពរថា លើកក្រោយមុននឹងហែរក្បួន ធ្វើអង្គប្រជុំ រឺឃោសនា សូមមេត្តាឱ្យដំណឹងមក PEC ដើម្បីសំរួលកម្មវិធីជូន ។ ទំនាស់មួយទៀត គឺកន្លែងលើកផ្លាកសញ្ញាគណបក្ស ការបិទខិតប័ណ្ណ បិទល្ងាច ស្អែកឡើងបាត់ នរណាទៅហែករបស់គ្នាបាត់ទៅ ជួនកាលឃើញគ្នាបិទហើយ ទៅបិទជាន់ពីលើគ្នា នាំឱ្យកើតមានជាបញ្ហា ។ គណបក្សខ្លះ ចងបាដារ ដែលគេហាមមិនឱ្យចងទទឹងថ្នល់ តែគាត់នៅចចេស ចងបាដារនោះ ទទឹងថ្នល់ ។

**ដំណាក់កាលទីបួន** គឺការរាប់សន្លឹកឆ្នោត នៅទីបញ្ចប់លោកបានបង្ហាញពីបញ្ហាចោទនានា ដូចជា ឈ្មោះអ្នកបោះឆ្នោតនៅក្នុងបញ្ជីដំបូង ការផ្ទៀងផ្ទាត់បញ្ជីឈ្មោះអ្នកបោះឆ្នោតរបស់ ស្មៀន ឈ្មោះមានស្ទួន ការប្តូរការិយាល័យបោះឆ្នោត បញ្ហាមេភូមិជួយរកឈ្មោះឱ្យអ្នកមិនចេះអក្សរ

វត្តមានមេភូមិនៅពេលបោះឆ្នោត ការគូស សន្លឹកឆ្នោត និងបញ្ហាប៊ិចមិនជិតជាដើម ។ លោកក៏បានទទួលស្គាល់ដែរថា នៅពេលបោះឆ្នោត មន្ត្រី គជប របស់លោក ក៏មានប្រើត្រាច្រឡំដែរ ។

**លោក ឱក សេរី សោភក្តិ៍** បានកោតសរសើរលោកប្រធាន PEC ដែលបានរាយការណ៍លំអិត ពីដំណាក់កាលមួយទៅមួយ ពីថ្នាក់មូលដ្ឋានទៅដល់ថ្នាក់ខេត្ត ។ លោកមានមោទនភាពណាស់ តាំងពីគ្រប់ដំណាក់កាលឃើញថា ខេត្តកណ្តាលធ្វើបានល្អច្រើនណាស់ ប៉ុន្តែ នៅខ្វះចន្លោះចំនុចខ្លះ ដែលអង្គប្រជុំទាំងមូល និងដកស្រង់បានបទពិសោធន៍ច្រើនបន្ថែមទៀតនៅព្រឹកនេះ ។

## ៤. មតិរបស់អ្នកចូលរួមដែលបង្ហាញអំពីការប្រឈមទាំងឡាយក្នុងយន្តការរៀបចំការបោះឆ្នោតក្នុងបរិបទខេត្តកណ្តាល

**លោក ស៊ុំ ផាត** ជំទប់ទី ១ នៃក្រុមប្រឹក្សាឃុំតាខ្មៅ តំណាងគណបក្ស សម រង្ស៊ី បានលើលបញ្ហា ៣ **ទី១.** កន្លងមក ការរៀបចំការបោះឆ្នោត មានគោលការណ៍ច្បាស់លាស់ មានថវិកា ការបែងចែក ទៅតាមខេត្ត តាមមណ្ឌលទាំងអស់ តែដល់ពេលប្រគល់ការងារ នេះឱ្យស្មៀងឃុំ គាត់ថាមានការងារច្រើន ដូចលោកប្រធាន គជប លើក ឃុំណាមានប្រជាជនច្រើន មានតំណាងស្មៀនមួយ និងជំនួយការ ២-៣ នាក់ តែមិនបានអនុវត្តដូច្នេះទេ ។រីឯថវិកាវិញ រាល់ការបោះឆ្នោត មានថវិកាគ្រប់គ្រាន់ ទើបអាចរៀបចំការបោះឆ្នោតបាន តែដល់ប្រគល់តួនាទី ទៅអាជ្ញាធរ ដែនដីអត់មានថវិកាសំរាប់ការចាត់ចែងជ្រើសរើស ភ្នាក់ងារបោះឆ្នោត ។ **ទី២.** យុទ្ធនាការឃោសនា គឺមានគោលការណ៍ច្បាស់ ពីក្រសួងមហាផ្ទៃមានក្រឹត្យច្បាប់ត្រឹមត្រូវ ដើម្បីឱ្យ គជប បញ្ជូនមកថ្នាក់ឃុំ ដែលជាអ្នកជូនពត៌មានទៅដល់តំណាងគណបក្សទាំងអស់ ។ កន្លងទៅ ការឃោសនានេះមានចែកជាកម្មវិធី តែកម្មវិធីនោះ មិនសុក្រឹត្យទេ គណបក្សនីមួយៗតែងមានអាជ្ញាធរដែលជួយអន្តរាគមន៍ ឯខាងគណបក្សលោកពេលយុទ្ធនាការម្តងៗ មិនមានតំណាងប៉ូលីសអាជ្ញាធរ ជួយអន្តរាគមន៍បើកផ្លូវឱ្យទេ ។ ដូច្នេះ សូមឱ្យ គជប គាត់ពិនិត្យរឿងនេះផង យ៉ាងណាមិញអាជ្ញាធរប៉ូលីស ជាអាជ្ញាកណ្តាល ឃើញថានៅមានការ ខ្វះខាត ។ **ទី៣.** លោកបានតាមដានការចុះឈ្មោះបោះឆ្នោត ៣អាណត្តិហើយ មន្ត្រី គជប (ក្រុមប្រឹក្សាឃុំ) ខ្លះចាស់ពេក គាត់ធ្វើការយឺត ។ លោកបានលើកជាឧទាហរណ៍ ជាក់ស្តែងថា មានប្រជាពលរដ្ឋខ្លះធុញ ដោយសារមកចាំចុះបញ្ជីឈ្មោះយូរពេក នេះជាការខ្វះខាតរបស់លោកមន្ត្រី រូបនោះ លោកសំណូមពរឱ្យប្រធាន គជប ពិនិត្យជ្រើសរើសអ្នកដែមានសមត្ថភាព ហើយជ្រើសរើសយកយុវវ័យ ដើម្បីឱ្យជួយតាមដានបញ្ជីឱ្យបាន ច្បាស់លាស់ ។

**លោក តុល ប្រាសាទ** តំណាងឯកឧត្តម ចាន់ចេង គណបក្ស សម រង្ស៊ី បានចូលរួមចែករំលែកបញ្ហានានាពាក់ព័ន្ធនឹងការបង្ការទំនាស់នាពេលបោះឆ្នោតខាងមុខ ។ កន្លងមកពិនិត្យឃើញថា មានបញ្ហាច្រើនពាក់ព័ន្ធនឹង ទំនាស់ អំពីការចុះឈ្មោះ រហូតដល់ការបោះឆ្នោត ការប្រកាសលទ្ធផលជា ផ្លូវការ ដែលកិច្ចការទាំងអស់នេះពាក់ព័ន្ធនឹង គជប ជាស្ថាប័នមួយដាច់ ដោយឡែកពីស្ថាប័នធំៗ ៣ នៃព្រះរាជាណាចក្រកម្ពុជា គឺជាស្ថាប័នមួយដែល រៀបចំឡើងដោយសភាជាតិ បានអនុម័តជ្រើសរើសតាំងពីថ្នាក់ជាតិ រហូតដល់ថ្នាក់មូលដ្ឋាន ដូចជា ថ្នាក់ឃុំ រឺ CEC ។

ដើម្បីឱ្យជៀសវាងទំនាស់ដែលកើតមានឡើងក្នុងពេលចាប់ផ្តើមចុះឈ្មោះ រហូតដល់ការបោះឆ្នោត និងការរាប់សន្លឹកឆ្នោត ប្រកាសលទ្ធផល ទំនាស់ច្រើនកើតពីគណបក្សនយោបាយ និងអាជ្ញាធរគ្រប់លំដាប់ថ្នាក់ រាប់ទាំងកងកំលាំងប្រដាប់ អាវុធទាំងពីរប្រភេទ បើសិន គជប អាជ្ញាធរ អភិបាល អភិបាលរងខេត្ត រឺស្រុក មេឃុំ មេភូមិ ព្រមទាំងកំលាំងប្រដាប់អាវុធទាំងពីរប្រភេទមាន ប៉ូលីស និងកងយោធពលខេមរៈភូមិន្ទរួមទាំងកងរាជអាវុធហត្ថផង យើងទាំងអស់គ្នាយល់ពីរដ្ឋធម្មនុញ្ញ ត្រូវគោរពគ្នាដូចម្តេច យល់ពីច្បាប់បោះឆ្នោត យល់ពីក្រមសីលធមិ លើសពីនេះ យើងដឹងពីពេលវេលា ព្រមទាំងយល់ទាំងអស់គ្នាថាតើត្រូវធ្វើដូចម្តេច នោះហើយជាកត្តាដែលយើងអាចជៀសវាងទំនាស់បាន ។ បើយើងទាំងអស់គ្នា

មិនគោរពច្បាប់ មានច្បាប់នៅក្នុងដៃ ហើយមិនអនុវត្ត ដែលបង្កើតឱ្យមានទំនាស់ជាហូរហែរកន្លងមក ។ ភាគច្រើននៃទំនាស់ដែលកើតមាននៅក្នុងខេត្តនេះ គឺមកពីការមិនគោរពច្បាប់បោះឆ្នោត និងមិនគោរពរដ្ឋធម្មនុញ្ញនេះឯង ។

កន្លងមកមានគណបក្សនយោបាយខ្លះ ដែលគណបក្ស សម រង្ស៊ី បានធ្វើការឃោនាពាក់ព័ន្ធនឹងទីតាំង បែរជាមានគណបក្សមួយទៀតអះអាងថា ទីតាំងហ្នឹងជាទីតាំងរបស់គណបក្សគាត់ទាវិញ ហេតុដូច្នេះហើយពិបាកយល់ ប៉ុន្តែគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត បានបញ្ជាក់ជាលាយល័ក្ខណ៍អក្សរថា ទីតាំងអព្យាក្រឹត្យ គណបក្សណាក៏អាចទៅឃោសនាកន្លែងនោះបានដែរ ។ នេះក្នុងច្បាប់បានចែងថា កន្លែងណាជាកន្លែងឯកជន កន្លែងណាជាកន្លែងសាធារណៈ ហើយកន្លែងណាដែលយើងគួរឃោសនាបាន ម៉ោងប៉ុន្មាន គឺមានកម្មវិធីជារៀងរហូត ។ ការឃោសនាការចុះឈ្មោះ ហើយមុននឹងធ្វើអ្វីៗដែលពាក់ព័ន្ធនឹងការបោះឆ្នោតកន្លងមក តែងតែជូនដំណឹង ឬពតិមានជូនទៅ គជប គ្រប់លំដាប់ថ្នាក់ ។ មួយវិញទៀតទាក់ទិននឹងបញ្ហាបាដារពាក្យស្លោក គណបក្សតូចតាច តែងគោរពក្រមសីលធមិនៃច្បាប់បោះឆ្នោត ដោយឡែកគណបក្សមួយចំនួនដែលអាងមានអំណាច ចងទទឹងផ្លូវតែម្តង នេះហើយដែលជាការមិនគោរពច្បាប់ នីតិវិធីនៃការបោះឆ្នោតនោះ ដូចលោក ប្រធាន PEC មានប្រសាសន៍ថា បាដារ គឺមិនអនុញ្ញាតឱ្យចងទទឹងផ្លូវទេ ។ ចំនុចមួទៀត ការលើកផ្លាកសញ្ញាភាគច្រើននៅតាមបណ្តាលឃុំស្រុកមួយចំនួនក្នុងខេត្តកណ្តាល អាជ្ញាធរ អត់យល់ពីនីតិវិធីនៅក្នុងការលើកផ្លាកសញ្ញានេះទេ អាជ្ញាធរតែងតែបង្ខំឱ្យគណបក្សនយោបាយសុំច្បាប់/គោលការណ៍ពីក្រសួងមហាផ្ទៃ គណបក្ស នយោបាយដែលលើកផ្លាកសញ្ញាមានទីតាំងរួចស្រេច ហើយទទួលបានការព្រមព្រៀងពីម្ចាស់ផ្ទះ ម្ចាស់កម្មសិទ្ធិ គឺគណបក្សនយោបាយនោះ គ្រាន់តែ ជូនដំណឹងទៅអាជ្ញាធរបានហើយ មិនចាំបាច់បង្ខំឱ្យទៅសុំច្បាប់ពីក្រសួងមហាផ្ទៃទៀតទេ ។ ដូច្នេះ លោកសំណូមពរថា អាជ្ញាធរគ្រប់លំដាប់ថ្នាក់ គួរតែយកចិត្តទុកដាក់ និងសហការទៅតាមគោលដៅនីមួយៗដែលបានកំណត់ ពិសេសបទបញ្ជា និងនីតិវិធីដែល គជប បានអនុម័ត ។

ចំណុចមួយទៀតពាក់ព័ន្ធនឹងការចុះឈ្មោះឆ្នោត ដែលការចុះឈ្មោះនេះ គឺធ្វើឡើងតាំងពីថ្ងៃទី១ ខែមករា ឆ្នាំ២០០៦ រហូតមកដល់ថ្ងៃនេះ គឺមានរយៈពេលជិតពីរខែហើយ ។ ការចុះឈ្មោះនេះ មានកង្វះខាត ។ កន្លងមក មានចំណាយលុយជាតិសន្លឹកសន្ធាប់ណាស់ ។ ហេតុនេះ គជប បានប្រគល់តួនាទីនេះ ទៅឱ្យក្រុមប្រឹក្សាឃុំ ស្មៀនឃុំ ។ មូលហេតុដែលនាំឱ្យមានបញ្ហា គឺលោកស្មៀនឃុំ មានធុរៈច្រើន ហើយការពិនិត្យឯកសារមានការរញ៉េរញ៉ៃ ក្នុងនោះមានច្រើនឃុំណាស់ដែលមានការលំបាកក្នុងការចុះឈ្មោះកន្លងមក ។ សុំនូមពររបស់គណបក្ស សម រង្ស៊ី គឺសុំឱ្យ**បង្កើតស្ថាប័នចុះឈ្មោះមួយឯករាជ្យ** ដាច់ដោយឡែកពីក្រុមប្រឹក្សាឃុំ ពីស្មៀនឃុំ ដែលធ្វើឱ្យការងារចុះឈ្មោះងាយស្រួល បង្កបរិយាកាសល្អដល់ប្រជាពលរដ្ឋដែលអញ្ជើញមកចុះឈ្មោះ ។ ឯរឿងរូបថត ពុំគួរណាឱ្យប្រជាពលរដ្ឋ យករូបថតមកដោយខ្លួនឯងទេ ព្រោះវាកាន់តែធ្វើឱ្យមានការលំបាកកាន់តែខ្លាំងនៅក្នុងបញ្ហានេះ ។

សំនូមពរ គួរតែមានស្ថាប័នឯករាជ្យ ហើយត្រូវមានម៉ាស៊ីនថតក្នុងមួយឃុំចំនួន ១ ឬ ២ ទៅឱ្យភ្នាក់ងារចុះឈ្មោះជូនប្រជាពលរដ្ឋ ថតឱ្យប្រជាពលរដ្ឋដែលអញ្ជើញទៅចុះឈ្មោះ ។ ប្រជាពលរដ្ឋដែលមានឯកសារគ្រប់គ្រាន់ ត្រូវថតរូបឱ្យគាត់ ចុះឈ្មោះឱ្យគាត់ ដើម្បីឱ្យគាត់មានប័ណ្ណបោះឆ្នោតពេលនោះតែម្តងទៅ ។ កុំចាំបាច់មានឯកសារគ្រប់គ្រាន់ ហើយខ្វះរូបថត ដេញត្រឡប់ទៅវិញ ដែលនេះជាបញ្ហាចោទកន្លងមក ហើយប្រជាពលរដ្ឋមួយចំនួនធុញ មិនត្រឡប់មកចុះឈ្មោះវិញទេ ដូច្នេះធ្វើឱ្យយើងខាតបង់សន្លឹកឆ្នោតច្រើនណាស់ ។ បន្ទាប់មកគឺ ពេលចាប់ផ្តើមចុះឈ្មោះបោះឆ្នោត និងរាប់សន្លឹកឆ្នោត គឺសុំឱ្យមានភាពសុក្រឹត្យ ធ្វើយ៉ាងណាឱ្យស្របទៅតាមច្បាប់ដែលបានកំណត់ ធ្វើយ៉ាងណាឱ្យសមរម្យ ផ្តល់លទ្ធភាពគ្រប់បែបយ៉ាងឱ្យដល់គណបក្ស មានសិទ្ធិគ្រប់គ្រាន់ ។

**លោក យារ ឡេង** មេឃុំកំពង់សំណាញ់ តំណាងគណបក្សប្រជាជនកម្ពុជា ខេត្តកណ្តាល លោកបានចូលរួមចំណែក ៦ចំណុច ។ **ទីមួយ** អំពីការចុះឈ្មោះបោះឆ្នោត មានការលំបាកខ្លាំងចាប់ពីឆ្នាំ១៩៩៣-២០០៣ មកតែរហូតដល់ឆ្នាំ២០០៤ ដែល គជប និងក្រសួងមហាផ្ទៃបានធ្វើប្រតិភូកម្ម

ឱ្យក្រុមប្រឹក្សា ឃុំនោះ ការចុះឈ្មោះមានភាពងាយស្រួល ប្រជាពលរដ្ឋបានមកចុះឈ្មោះតាម លំដាប់លំដោយ ដែលបង្ហាញពីភាពប្រសើរឡើង នៃដំណើរការចុះ ឈ្មោះបោះឆ្នោត ។ **ទីពីរ** ការឃោសនារបស់គណបក្ស ចំណុចខ្វះខាតមានច្រើន ដូចជា គណបក្សនយោបាយ និងអង្គការមួយចំនួន មិនយល់ដឹងច្បាស់អំពីក្រមសីលធមិ ដែលកំណត់ដោយក្រសួងមហាផ្ទៃ និង គជប ។ ជាក់ស្តែង គណបក្សប្រជាជនក្នុងកំឡុងពេលឃោសនាបោះឆ្នោត មានអង្គការខ្លះអត់ពាក់ផ្លាកធ្វើសកម្មភាពជាមួយគណបក្សនយោបាយខ្លះនៅមូលដ្ឋានឃុំ ដូច្នេះឃុំក៏បានសួររកលិខិតឧទ្ទេសនាម ស្រាប់តែគេសួរវិញ ថា លោកមានសិទ្ធិអី សួររកលិខិតឧទ្ទេសនាម លោកតបថា ក្រសួងមហាផ្ទៃ និង គជប ប្រតិភូកម្មអំណាចឱ្យដូច្នេះមានសិទ្ធិសួរ អត់ខុសទេ ។

ដូច្នេះឆ្នាំ២០០៧ និង២០០៨ សូមកុំឱ្យរឿងបែបនេះកើតឡើងទៀត អ្វីដែល គជប ក៏ដូចជា ក្រសួង មហាផ្ទៃ ដាក់មកឱ្យទទួលស្គាល់ទាំងអស់គ្នា ដើម្បីឱ្យមាននិរន្តរភាពទាំងអស់គ្នា ងាយស្រួលក្នុងបញ្ហាបំពេញភារកិច្ច ។ បញ្ហាមួយទៀត ដាក់សំណើមកថា សុំឃោសនា នៅកន្លែងនេះ វេលាម៉ោងប៉ុណ្ណេះ ប៉ុន្តែអត់មកតាមកំណត់ទេ នេះហើយជាបញ្ហាពិបាក តើឱ្យសមត្ថកិច្ចទៅការពារទីណា បើកម្មវិធីដាក់ថ្ងៃ២០ ស្រាប់តែចេញមកថ្ងៃ១៨ ហើយថ្ងៃ ១៨ គណបក្សមួយទៀត ធ្វើការឃោសនានៅកន្លែងនោះដែរ ។ **ទីបី** និយាយ ពីថ្ងៃបោះឆ្នោត ក្នុងនាមលោកជាប្រជាពលរដ្ឋម្នាក់ ថ្ងៃទៅបោះឆ្នោត លោកបានទៅចាំតាមលេខរៀង លោកឈរនៅមាត់ទ្វារ ស្រាប់តែអនុប្រធាន CEC ឱ្យហៅលោកចេញវិញថា លោកគ្មានសិទ្ធិទៅឈរនៅមុខបន្ទប់បោះឆ្នោតទេ ។ បើតាមច្បាប់ ប្រជាពលរដ្ឋណា ក៏ដូចប្រជាពលរដ្ឋណា មានសិទ្ធិទៅឈរនៅក្រៅបរិវេណបោះឆ្នោត មិនចូលក្នុងការិយាល័យបោះឆ្នោត អត់ទាន់បានបោះឆ្នោតផង ហៅឱ្យចេញវិញ ។ **ទីបួន** និយាយពីបញ្ហាចាត់តាំងអ្នកសង្កេតការណ៍ ធម្មតាគណបក្សនយោបាយសុទ្ធតែមានទាំងអស់ ហេតុអ្វីបានជាចោទថា មានគណបក្សនេះបន្លំ គណបក្សនោះបន្លំ បើមិនទុកចិត្តគណបក្សនយោបាយរបស់ខ្លួន គួរចាត់តាំងអ្នកដែលមានកិរិតថ្នាក់ណាដែលទទួលបាន ដើម្បីជៀសវាងថា ចុះហត្ថលេខាទទួលស្គាល់ហើយ ស្រាប់តែមកចោទគណបក្សឈ្នះឆ្នោតថា លួចបន្លំទៅវិញ ។ **ទីប្រាំ** អង្គការនានាចូលតាមដានសង្កេតការណ៍ ត្រួតពិនិត្យគ្រប់ការិយាល័យទាំងអស់ តែនៅតែមិនទទួលស្គាល់ ថាតើគួរបំបាត់ ចោលទេដែលភាគច្រើនអង្គការមួយចំនួន តាមដានតែគណបក្ស កាន់អំណាច ហើយថាគណបក្សឈ្នះឆ្នោតលួចបន្លំ ដូច្នេះសុំបំបាត់ចោលបញ្ហានេះ ។ **ប្រាំមួយ** ថ្ងៃរាប់សន្លឹកឆ្នោត ក្នុងនាមជាប្រជាជនខ្មែរម្នាក់ លោកក៏បានទៅមើល តែគេមិនឱ្យ គេសួថា លោកមានសិទ្ធិអីមកអើតហ្នឹង សួរថាអនុក្រឹត្យនៃ ច្បាប់មាត្រាទីប៉ុន្មានដែលមិនឱ្យទៅជិត វាអត់មាន ដល់ខ្លួនឯង ១០នាក់អាចមកបាន ។ ដូច្នេះសូមបោះចោលគោលការណ៍ ដែលខុសឆ្គងទាំងអស់ នេះ ហើយយកជាបទពិសោធន៍សំរាប់ឆ្នាំ២០០៧ និងឆ្នាំ២០០៨ ។

**លោក ឱក សេរី សោភក្តិ៍** បញ្ជាក់ប្រាប់អង្គប្រជុំថា យន្តការខប់សែល បានសំរេចឡើង គឺអ្វីដែលយើងទើបនឹងបានឃើញ យើងបានស្តាប់ដែល តំណាងគណបក្ស សម រង្ស៊ី ពីររូបដែលលោកមានប្រសាសន៍អំពីបញ្ហាដែលលោកកង្វល់ ហើយបានស្តាប់តំណាងខាងគណបក្សប្រជាជនកម្ពុជា លោក លើកឡើងវិញ បញ្ហាដែលលោកកង្វល់ដែរ នេះហើយដែលយន្តការខប់សែល មានមោទនភាព ដែលបានស្តាប់នៅលើតុតែម្តង ត្រង់ទៅត្រង់មកតែម្តង ហើយយើងអត់ចាំបាច់ទៅនិយាយគ្នាពីក្រោយខ្នងទេ យើងនិយាយគ្នាមុខហ្នឹង តែកាលណាយើងនិយាយអស់ចិត្តហើយ គឺមានមន្ទិលសង្ស័យ ទៀតទេ ហើយខាង PEC ក៏នឹងអាចទទួលយកទៅធ្វើការបាន ខាងខប់សែលក៏អាចនឹងទទួលយកទៅហើយចែករំលែកប្រាប់ទៅខេត្តគេផ្សេងៗ ទៀតហ្នឹងហើយដែលជា វប្បធមិនៃការជជែកពិភាក្សាគ្នានោះ ។

**លោក ចយ សុបិន** អភិបាលរងស្រុកកោះធំ លោកបានចាប់អារម្មណលើការងារ ៣ចំនុច ។ **ទីមួយ** ការចុះឈ្មោះបោះឆ្នោត និងពិនិត្យបញ្ជីបោះឆ្នោត យើងតែងឮការចោទប្រកាន់គ្នាថា ការចុះឈ្មោះបោះឆ្នោតនេះ មិនបានអស់គ្នា ដោយសារមន្ត្រីគណបក្សនេះ ឬគណបក្សនោះរារាំង ។ ដោយ ឡែក នៅស្រុកកោះធំ គណបក្សសំខាន់ៗ ៣ សុទ្ធតែមានអាសនៈនៅក្រុមប្រឹក្សាឃុំទាំងអស់ ។ ឥឡូវនេះ ការចុះឈ្មោះត្រៀម ក្រុមប្រឹក្សាឃុំ នីមួយៗ តែងតែយកបញ្ហាពេលប្រជុំផ្សព្វផ្សាយនៅ ក្រុមប្រឹក្សាឃុំ ពេលនោះក្នុងនាមជាសមាជិកក្រុមប្រឹក្សាឃុំ តំណាងឱ្យគណបក្ស

ណាមួយនោះ គួរតែជួយទាំងអស់គ្នា កុំអង្គុយចាំស្រែក ។ ពេលចេញ ពីប្រជុំមកវិញ យើងមានតួនាទី និងភារកិច្ចដូចគ្នា សមាជិកក្រុមប្រឹក្សាឃុំទាំងអស់ធ្វើ យ៉ាងណា បំផុសឱ្យប្រជាពលរដ្ឋទាំងអស់នៅក្នុងភូមិ ឃុំ បានមកចុះឈ្មោះ និងពិនិត្យឈ្មោះគ្រប់ៗគ្នា ។ ដូចលោកប្រធាន PEC លើកឡើង អ្នកខ្លះ អត់មកមើលអីទេ អាងតែមានឈ្មោះហើយ តែដល់ថ្ងៃ បោះឆ្នោត ស្រែកជំទាលនៅពេលដែលរកឈ្មោះមិនឃើញ ។ ដូច្នេះតទៅ ពេលដែលបាន ទទួលសេចក្តីជូនដំណឹងពី PEC ក្រុមប្រឹក្សាឃុំទាំងអស់ ត្រូវតែអនុវត្តឱ្យបានគ្រប់គ្នា ។ **ទីពីរ** អំពីយុទ្ធនាការឃោសនាបោះឆ្នោតឃើញថា គណបក្សមួយចំនួន មិនគោរពតាមគោលការណ៍ក្រមសីលធមិទេ  ដូចជាការធ្វើការឃោសនានៅថ្ងៃស ដែលជាថ្ងៃហាមឃាត់ ដែលធ្វើឱ្យមានភាពពិបាកទៅដល់អាជ្ញាធរ  ក្នុងការចាត់ចែងកំលាំងឱ្យតាមការពារ  ។ **ទីបី**  ទាំងថ្ងៃបោះឆ្នោត  និងរាប់សន្លឹកឆ្នោត  សុទ្ធតែមានតំណាងអាជ្ញាធរ គណបក្សនយោបាយ សង្គមស៊ីវិលដើរពិនិត្យមើលគ្រប់ទីកន្លែង ប៉ុន្តែក្រោយមកចេះតែឮ មានបាតុភាពមិនប្រក្រតី ដែលធ្វើឱ្យអាជ្ញាធរពិបាកនៅក្នុងបញ្ហានេះ ។

**លោកស្រី មួង ជាច័ន្ទមុន្នី** សមាជិកក្រុមប្រឹក្សាឃុំតាខ្មៅ គណបក្ស សម រង្ស៊ី បាមសំណូមពរឱ្យមានសមាសភាពស្រ្តីនៅក្នុង គជបឱ្យបានច្រើនបន្តិច ព្រោះទំនាស់ខ្លះ បុរសមិនអាចដោះស្រាយបានទេ ព្រោះខ្លាចមាន ការវាយតប់ ឬមានអំពើហឹង្សាផ្សេងៗពីសំណាក់បុរស ។ ស្រ្តីអាចជួយអប់រំក្រុមស្រ្តីដូចគ្នា ឱ្យយល់ដឹងពីច្បាប់បោះឆ្នោត ពេលដែលមិនយល់ពីដំណើរការ បោះឆ្នោត គាត់ហ៊ានសួរ ចំណែកបុរស ជួនកាលមានចរិតច្រងែងច្រងាង ដែលស្រ្តីគាត់មិនហ៊ានសួរ នេះហើយជាបញ្ហាដែលធ្វើឱ្យមានការស្រពេច ស្រពិលនៅពេលបោះឆ្នោត ដែលបញ្ហាទាំងនេះតែងកើតមានកន្លងមក ។ ពាក់ព័ន្ធនឹងការគូស និងរាប់សន្លឹកឆ្នោត សូមធ្វើយ៉ាងណាឱ្យពតិមាននោះឮ ដល់ប្រជាពលរដ្ឋដែលជាម្ចាស់សន្លឹកឆ្នោតឱ្យបានយល់ពីសន្លឹកឆ្នោតបានការ និងសន្លឹកឆ្នោតមិនបានការ ជៀសវាងដល់ពេលរាប់សន្លឹកឆ្នោត ជូនជា លទ្ធផលហើយនោះ និងមានការជជែកគ្នា រវាងគណបក្សដែលមានវត្តមាននៅថ្ងៃរាប់សន្លឹកឆ្នោតនោះ ។ លោកស្រី បានគាំទ្រប្រសាសន៍របស់លោក អភិបាលរងស្រុកកោះធំ ប្រសិនជាអាចធ្វើបានទូទាំងខេត្តកណ្តាល ១៤៧ឃុំ ជាការល្អណាស់ ។ លោកស្រីបានបន្តថា ច្បាប់បោះឆ្នោតបានចែងពី សិទ្ធិស្មើគ្នា រវាងបុរស និងស្រ្តី នៅក្នុងគណបក្សនយោបាយ  ប៉ុន្តែជាក់ស្តែងមានតែបុរសទេដែលគ្រប់គ្រងអំណាចក្នុងកិច្ចការផ្សេងៗ  ។ ដូច្នេះ  សំណូមពររបស់លោកស្រីទៅខាងរដ្ឋសភាជាតិ និងព្រឹទ្ធសភា ដែលទើបតែបង្កើតថ្មីនៅអាណត្តិទី២ គួរតែកែប្រែ ឬបន្ថែមច្បាប់យ៉ាងណា ដើម្បីឱ្យស្រ្តី មានចំនួនស្មើនឹងចំនួនបុរស ។ សំខាន់មួយទៀត លោកស្រីបានសំណូមពរទៅរាជរដ្ឋាភិបាល តើលោកអាចការពារសុវត្ថិភាពស្រ្តីបានទេ ព្រោះស្រ្តីឈរឈ្មោះក្នុងគណបក្ស ដើម្បីចូលកាន់អំណាចចូលកាន់តំណែងនៅក្នុងមូលដ្ឋាន ក៏ដូចជាសិទ្ធិកំពូលថ្នាក់ជាតិដែរ ចុះបើសិនជាមានការគំរាម កំហែងដល់ស្រ្តី មានអំពើហឹង្សាលើស្រ្តី ជាក់ស្តែងក្នុងគ្រួសារខ្លះ បុរសជាប្តី មិនពេញចិត្តឱ្យប្រពន្ធចូលប្រឡូកក្នុងនយោបាយទេ តើគួរធ្វើយ៉ាងម៉េច? បញ្ហាចុះឈ្មោះគ្មានរូបថត តើឱ្យប្រជាជនចំណាយថវិកាផ្ទាល់ខ្លួនឬយ៉ាងណា បើក្នុងមួយគ្រួសារមានគ្នា ៦នាក់ ដូច្នេះដើម្បីជៀសវាងនូវការបាត់ សន្លឹកឆ្នោត សូមកុំឱ្យប្រជាជនថតរូបខ្លួនឯង ។

**លោក មឿង សោភណ្ឌ**  ជំទប់ទីមួយ ឃុំដើមមៀន ស្រុកតាខ្មៅ គណបក្ស សម រង្ស៊ី លោកបានលើកឡើងនូវបញ្ហាបី ។ **ទីមួយ** ពីការចុះ ឈ្មោះបោះឆ្នោត តាមសង្កេតកន្លងមកនៅស្រុកតាខ្មៅ ការចុះឈ្មោះបោះឆ្នោតតាមច្បាប់ថា អ្នកណានៅមូលដ្ឋានណា ចុះឈ្មោះក្នុងមូលដ្ឋាននោះ ជាក់ស្តែង នៅក្នុងបន្ទាយទួលក្រសាំង បន្ទាយលោកនាយករដ្ឋមន្ត្រី បានចុះដាក់វាយកំលាំង គ្រប់ឃុំទាំងអស់ នៅស្រុកតាខ្មៅ បើមិនច្រឡំទេ ក្នុងបន្ទាយនេះ គឺក្នុងភូមិសាស្រ្តឃុំតាខ្មៅទេ ក្នុងឆ្នាំ១៩៩៨ ។ តែក្រោយមកឆ្នាំ២០០២-២០០៣ គាត់ប្រែរូបភាពផ្សេងដោយស្លៀកពាក់ស៊ីវិលធម្មតាកាន់ឯកសារអីមកចុះឈ្មោះបោះឆ្នោត ពេលបោះឆ្នោតបានដឹកមនុស្សមកជាក្បួនរថយន្តតែម្តង នេះជា សកម្មភាពឃើញកន្លងមក ។ **ទីពីរ** ការចុះឈ្មោះបោះឆ្នោត តាមរយៈការប្រជុំ ខប់សែល នៅភ្នំពេញកន្លងមកគឺ ឯកឧត្តម ព្រុំ សុខា បានលើកដែរថា ការចុះឈ្មោះបោះឆ្នោតកន្លងមកចំនាយថវិកាតិច ហើយក្រោយមកបានស្តាប់របាយការណ៍របស់ប្រធាន PEC ក៏បានលើកដែរថា ការបោះឆ្នោតបីអណត្តិកន្លងមក ការចំណាយថវិកា

មានការថយចុះ តែបើនិយាយពីគុណភាពវិញឆ្នាំ១៩៩៣ ថា ម្នាក់ចំណាយ ៥ដុល្លារ ប៉ុន្តែ ៥ដុល្លារ គេមានប័ណ្ណត្រឹមត្រូវមានរូបថត មានអុតរឹង ដល់ឆ្នាំ១៩៩៨ ចំនាយម្នាក់អស់តែ ៤ដុល្លារបានប័ណ្ណដែរ តែអត់ល្អ មានអ៊ិតត្រឹមត្រូវដែរ ដល់ទៅឆ្នាំ២០០២ បោះឆ្នោតក្រុមប្រឹក្សាឃុំសង្កាត់ ចំណាយអស់ ៣ដុល្លារ ប័ណ្ណកាន់តែអន់ ជួនកាលមានអ៊ិត ជួនកាលអត់អ៊ិត ហើយអត់រូបថត ដល់ឆ្នាំ២០០៣ កាន់តែអន់មែនទែន ចំណាយអស់តែ ២,១១ដុល្លារ នៅពេលធ្វើ១០-១៨ បិទរូបថត យករូបថតខ្លួនឯង ។ ជាសំនូមពរ សូមឱ្យធ្វើប្រហែលឆ្នាំ១៩៩៨ អត់ខាតទេ ព្រោះក្នុងការចុះឈ្មោះបោះឆ្នោតនេះ មិនពិបាកឃោសនារកអ្នកចុះឈ្មោះបោះឆ្នោតនោះទេ ព្រោះអ្នកគ្រប់អាយុ ១៨ឆ្នាំ ចង់ណាស់ មិនត្រឹមតែចង់បោះឆ្នោតទេ ចង់ទៅរកការងារធ្វើទៀត ចង់យកប័ណ្ណបោះឆ្នោតទៅចូលរោងចក្រ ពិសេស ខាងស្ត្រីចង់បានប័ណ្ណនេះណាស់ ការចុះឈ្មោះបោះឆ្នោតនេះ វាគ្មានបញ្ហាអីទេដល់ឆ្នាំ២០០៣ លោកប្រធាន PEC ថា ឱ្យអស់តិច អស់តិចក៏ឯកភាព ដែរ តែក្រដាសដែលបាននោះ មានគុណភាពវាអន់ដែរ រូបថតខ្លួនឯង ជួនកាលក្រដាសយកទៅ ប្រជាពលរដ្ឋយកទៅរក្សាទុកបានស្អាតល្អដែរ តែឆាប់ខូច ។ ក្រោយពីបានឮលោក អ្នកសម្របសម្រួលថា បញ្ហាអត្តសញ្ញាណប័ណ្ណ នឹងជំរុញធ្វើឱ្យបានក្នុងរយៈពេល ៣ឆ្នាំខាងមុខនេះ ពិតជា ត្រេកអរណាស់សំរាប់ប្រជាជនយើង ព្រោះមានការខូះខាតច្រើនណាស់កន្លងមក ។ **ទីបី** នៅពេលបោះឆ្នោត តាមការិយាល័យនីមួយៗ មានលោក មេភូមិដែលតំណាងឱ្យភូមិរបស់គាត់ បានយកបញ្ជីការិយាល័យ ក១ ឬ ខ១ យកមកកាន់ ពេលប្រជាជនដើរទៅ គាត់ប្រាប់ថា យកសិនទៅ នេះយកលេខរៀងដើម្បីស្រួលបោះ យើងឯកភាពថា សំរួលដល់ប្រជាជន ប៉ុន្តែ ពេលនោះឆក់ឱកាសបន្តិច ដើម្បីប្រាប់ថា គណបក្សណានៅ លេខរៀងទីប៉ុន្មាន ហើយបញ្ហានេះក៏បានសំនូមពរដល់លោកប្រធាន CECហើយដែរ គាត់ក៏បានទៅប្រាប់ទៅខាងមេភូមិដែរ តែមិនព្រមឈប់ទេ។ **ទីបួន** បញ្ហាឃោនាស បោះឆ្នោត គណបក្សសមរង្ស៊ី ដូចជាវេទនាជាងគេបន្តិច ក្នុងវត្តព្រៃកប្បស្ស៊ី ទី១ និងទី២ គ្រាន់តែសុំឈប់ហូប បាយថ្ងៃត្រង់មិនឱ្យ មិនដឹងជាគាត់ខឹង រឿងអីទេ ហើយបានសុំទាំងអាចារ្យវត្តទៀតផង ដើម្បីឈប់សំរាក ព្រោះពេលឃោសនាក្រមសីលធម៌ ពីម៉ោង ប៉ុន្មាន ដល់ម៉ោងប៉ុន្មាន យើងដឹង ហើយដល់ម៉ោងឈប់សំរាក គឺឈប់ តែគាត់អត់ផ្តល់ឱកាសឱ្យយើងទេ ។

**លោក ទួន សឿន** ឃុំស្វាយប្រទាល ស្រុកស្អាង គណបក្សប្រជាជនកម្ពុជា ដោយបានស្តាប់ខាងតំណាងគណបក្ស សម រង្ស៊ី ប្រចាំខេត្តស្តីពីឱ្យគោរព គោលការណ៍រដ្ឋធម្មនុញ្ញ ក៏ដូចជាក្រមសីលធម៌ ការចងបាដារកន្លងមក គាត់លើកឡើងថា មានតែគណបក្សកាន់អំណាចទេដែលមិនគោរពច្បាប់ ចងបាដារទទឹងផ្លូវ ជាក់ស្តែងនៅឃុំស្វាយប្រទាល គឺគណបក្ស សម រង្ស៊ី ចងបាដារទទឹងផ្លូវ ទោះជាឱ្យ CEC ប្រាប់ ក៏មិនព្រមស្រាយដែរ ដែលបាដារនោះមានខ្លឹមសារថា " អំណោយរស់បានមួយថ្ងៃប្រជាធិតេយ្យរស់បានមួយជីវិត " ។ បញ្ហាក្រមសីលធម៌ នៅពេលយុទ្ធនាការឃោសនាបោះឆ្នោត សូមឱ្យជៀសវាងនូវការជេរគ្នាតាមមេក្រូ ព្រោះបទបញ្ជាផ្ទៃក្នុងរបស់គណៈកម្មាធិការជាតិប្រចាំឃុំ គេហាមមិនឱ្យបំពងសម្លេងឧឃោសនស័ព្ទប្រហែលជា ៥០ម៉ែត្រ ចេញពីស្នាក់ការរបស់ គណបក្សដទៃ គ្រប់គណបក្សតែដល់ពេលឃោសនាដល់ជិតកន្លែងទីស្នាក់ការគេ យើងត្រូវបិទឧឃោសនស័ព្ទសិន ពេលផុតទើបឃោសនាបន្តទៀត តែផ្ទុយទៅវិញ មិនត្រឹមតែថែមសម្លេងបំពងទេ មានពេលខ្លះ គេទៅឈប់ឡានទៅមុខស្នាក់ការគេ ហើយជេរនៅមុខស្នាក់ការតែម្តង មូលហេតុនេះ ហើយដែលនាំឱ្យមានទំនាស់កន្លងមក ហើយបែរជាថា គណបក្សប្រជាជនទៅវិញ ដូច្នេះសូមជៀសវាង កុំស៊ីចេកយកលាបមាត់ពពែ ។

**លោក ឃុន ផាត** ជំទប់ទី២ ឃុំព្រៃកប្បស្ស៊ី គណបក្ស សម រង្ស៊ី **បញ្ហាទីមួយ** លោកចាប់អារម្មណ៍ថា តាមច្បាប់ចុះឈ្មោះបោះឆ្នោតក្រសួងមហាផ្ទៃបានធ្វើប្រតិភូកម្មឱ្យក្រុមប្រឹក្សាឃុំ មេឃុំជាអ្នកចុះហត្ថលេខាលើ ឯកសាផ្សេងៗ ដើម្បីចុះឈ្មោះបោះឆ្នោត ចំណុចខ្វះខាតត្រង់នេះ សូមសួរទៅខាង PEC តើមេឃុំ ពេលដែលគាត់មិននៅ គាត់មិនបានផ្ទេរសិទ្ធិទៅ ជំទប់ទី១ ទី២ ទេ អញ្ចឹងគាត់ចុះហត្ថលេខាលើឯកសារទុកតែម្តង គាត់ចុះហត្ថលេខាហើយជាស្រេច ហើយគាត់ទុកឱ្យជំនួយការគាត់ម្នាក់ចាំ ប្រថាប់ត្រា ពេលមានប្រជាពលរដ្ឋមកចុះឈ្មោះបោះឆ្នោត គ្រាន់តែជំនួយ

ការបំពេញ ហើយបោះត្រាពីលើជាការស្រេច អញ្ចឹងជំទប់ទី១ ជំទប់ទី២ អត់មានការធ្វើរហូត ។ **ទី២** រឿងសំបុត្រកំណើតក្លែងក្លាយ ដើម្បីបំពេញឯកសារចុះឈ្មោះបោះឆ្នោតបាន ស្មៀនគេដឹងច្បាប់របស់គេ ត្រូវមានលិខិត ឯកសារដែលជាសញ្ជាតិខ្មែរ ដែលក្នុងនោះមានសៀវភៅគ្រួសារ សំបុត្រកំណើត ដូច្នេះដើម្បីជៀសវាងបញ្ហា មេឃុំ និងស្មៀនមិនព្រមចុះឈ្មោះឱ្យ អញ្ចឹងគាត់ទៅបំពេញសំបុត្រកំណើតក្លែងក្លាយឱ្យមួយ គ្រាន់តែបំពេញជាឯកសារឱ្យចុះឈ្មោះទេ អត់បានចុះក្នុងបញ្ជីសំបុត្រកំណើតទេ ចំពោះ ប្រជាពលរដ្ឋនៅក្រៅមូលដ្ឋាន ហើយគាត់ចង់ចុះឈ្មោះក្នុង មូលដ្ឋានហ្នឹង គាត់ក៏បំពេញសំបុត្រកំណើតក្លែងក្លាយនេះឱ្យមួយ អត់មានគល់បញ្ជីទេ ។ **ចំនុចទី៣** ការិយាល័យចល័ត ពេលចុះឈ្មោះបោះឆ្នោត ចំពោះមេឃុំ ដែលមានភូមិដាច់ស្រយាល ដែលត្រូវរើការិយាល័យទៅភូមិមួយទៀតដែល នៅឆ្ងាយពីសាលាឃុំ ហើយមេឃុំគាត់អត់ចល័តបានទេ អញ្ចឹងវានាំឱ្យមានផលវិបាកដល់ប្រជាពលរដ្ឋ ដែលគាត់មកចុះឈ្មោះនោះ ពេលទៅចុះឈ្មោះ គាត់ខ្វះឯកសារ គាត់រត់ទៅសាលាឃុំសិន អ្នកខ្លះគេអត់ មានមធ្យោបាយធ្វើដំណើរទេ គាត់ត្រូវជិះម៉ូតូឌុប ១.000រៀល ទៅឱ្យ មេឃុំចុះហត្ថលេខា ហើយជិះម៉ូតូឌុប ១.000រៀលមកវិញ មកចុះឈ្មោះនៅ កន្លែងស្មៀននេះទៀត អញ្ចឹងត្រឡប់ទៅ ត្រឡប់មក ធ្វើឱ្យមានផលវិបាក អ្នកខ្លះគាត់ខ្ជិលផង ហើយអត់លុយផងទៅទៀត ខ្ជិលចុះតែម្តង ។

**លោក ម៉ក់ ប៊ុនស្រ៊ុន** ក្រុមប្រឹក្សាឃុំត្រើយស្លា ស្រុកស្អាង ខេត្តកណ្តាល គណបក្សហ៊្វុនស៊ិនប៉ិច លោកបានចូលរួមជាអនុសាសន៍បី ចំនុច ។ **ទីមួយ** ដើម្បីឱ្យប្រជាពលរដ្ឋមានសិទ្ធិទៅចូលរួមការបោះឆ្នោត លុះត្រាតែបានបំពេញឈ្មោះបោះឆ្នោត នៅក្នុងបញ្ជីបោះឆ្នោត ដូចនេះដើម្បីឱ្យគាត់ មានលក្ខណៈងាយស្រួលនៅក្នុងការបោះឆ្នោត តើត្រូវធ្វើយ៉ាងដូចម្តេច យើងដឹងហើយថា នៅក្នុង គណៈកម្មាធិការរៀបចំការបោះឆ្នោតកន្លងមកនេះ មន្ត្រីនៅមូលដ្ឋានចុះឈ្មោះបោះឆ្នោត សុទ្ធតែរើសចេញពីគណបក្សនយោបាយទាំងបី ដូចនេះ ប្រជាពលរដ្ឋដែលទៅចុះឈ្មោះនោះ ទោះបីជាយ៉ាងណា ពេលមានបញ្ហារអាក់រអួលបន្តិចបន្តួច គាត់តែងតែលាបពណ៌ទៅលើបញ្ហាគណបក្ស ។ ដូចនេះ ដើម្បីកុំឱ្យមានការមិនទុកចិត្តពីប្រជាពលរដ្ឋ សូមសំណូមពរមួយថា គួរតែបង្កើតស្ថាប័នឯករាជ្យមួយ ដោយមិនពាក់ព័ន្ធនឹង គណបក្សនយោបាយ មានន័យថា គួរតែបង្កើតសង្គមស៊ីវិលមួយ សំរាប់ផ្តល់អាទិភាពដល់ប្រជាពលរដ្ឋសំរាប់ការចុះឈ្មោះ ដើម្បីកុំឱ្យមានអារម្មណ៍មិនទុកចិត្ត ។ **ទី២** បញ្ហានីតិវិធីនៃការចុះឈ្មោះបោះឆ្នោត សំណូមពរឱ្យមន្ត្រីដែលចុះឈ្មោះនោះ គោរពទៅតាមច្បាប់នីតិវិធីនៃការបោះឆ្នោត ។ **ទី៣** ពេលបោះ ឆ្នោត សំណូមពរថា នៅក្នុងបរិវេនបោះឆ្នោត អ្នកណាដែលគ្មានតួនាទី គួរតែកុំនៅក្បែរកន្លែងមើលឈ្មោះបោះឆ្នោត ហើយសូមឱ្យ គណៈកម្មាធិការរៀបចំការបោះឆ្នោតមានកំលាំងរបស់ខ្លួនក្នុងការអន្តរាគមន៍ មើលឈ្មោះឱ្យប្រជាពលរដ្ឋ នេះហើយជាចំនុចល្អ ដើម្បីកុំឱ្យ ប្រជាពលរដ្ឋមាន អារម្មណ៍យ៉ាងណាៗនោះ ។

**លោក គួន ងួន** អនុប្រធានមន្ទីរពត៌មានខេត្តកណ្តាល លោកបានចាប់ចំណាប់អារម្មណ៍ទៅលើ ៣ចំនុច និងសំនួមពរមួយ ។ **ទី១** គឺយើងទាំងអស់ គ្នាគួរតែរកឱ្យឃើញថា បុព្វហេតុជាសារវន្តដែលនាំឱ្យ កកើតទៅជាទំនាស់ ។ **ទី២** យើងត្រូវតែទទួលស្គាល់ទាំងអស់គ្នាថា ទំនាស់នោះបានជះឥទ្ធិពល និងផ្តល់ផលវិបាកធ្ងន់ធ្ងរមកលើសង្គមជាតិយើង នៅពេលដែលយើងស្គាល់ពីឥទ្ធិពល និងឫសគល់របស់វា យើងនឹងពួតដៃគ្នាដើម្បីរកវិធីបង្ការ ប្រៀបបីដូចជាបង្ការជំងឺអេដស៍អញ្ចឹង ។ **ទី៣** ក្នុងនាមអស់លោកដែលសុទ្ធតែជាសកម្មជន សុទ្ធតែជាអ្នកដឹកនាំ ស្គាល់ពីនីតិវិធីគ្រប់គ្រាន់ក្នុងការបង្ការ ទំនាស់នោះ ជាសំនួមពរ ក្នុងនាមយើងជាខ្មែរ ទាំងអស់គ្នាត្រូវតែខិតខំពួតដៃគ្នា ប្រែក្លាយការប្រកួតប្រជែងនោះ ឱ្យទៅជាកម្មវត្ថុ និងជាគោលដៅនៃ ការកសាងវប្បធម៌សន្តិភាព ស្ថិរភាព និងការអភិវឌ្ឍន៍ ដើម្បីធ្វើឱ្យប្រទេសយើង មានសមត្ថភាព និងមានតុល្យភាពក្នុងការប្រកួតប្រជែងជាមួយ បណ្តាប្រទេសនៅក្នុងតំបន់អាស៊ាន ។

**លោក អួង សុខអាន** ជំទប់ទី២ ឃុំដើមមៀន គណបក្សហ៊្វុនស៊ិនប៉ិច លោកសំនួមពរគណៈកម្មាធិការជាតិរៀបការបោះឆ្នោត ២ចំនុច និងសូមឱ្យអង្គការមិនមែនរដ្ឋាភិបាលជួយពិចារណា ។ **ទីមួយ** ចំណុចខ្វះខាតកន្លងមកចំពោះអ្នកបោះឆ្នោត បើតាមនីតិវិធី គឺយើងមានប្រជា

ពលរដ្ឋលុះត្រាណាមានឈ្មោះនៅក្នុងបញ្ជីបោះឆ្នោតទើបអាចបោះឆ្នោតបាន  ក៏ប៉ុន្តែប្រជាពលរដ្ឋមួយចំនួនគាត់បានចុះឈ្មោះមានបង្កាន់ដៃ  ក៏ទៅចុះឈ្មោះបោះឆ្នោតនៅក្នុងការិយាល័យណាមួយគាត់ទៅពិនិត្យមើលឈ្មោះរបស់គាត់   គឺមាននៅក្នុងបញ្ជីពេលគាត់បញ្ជ្រៀតចូលទៅដល់ការិយាល័យដើម្បីបោះឆ្នោត  អ្នកបំរើការនៅក្នុងនោះថាឈ្មោះគាត់ត្រូវបានគេបោះរួចហើយ  ពេលយើងពិនិត្យក្នុងបង្កាន់ដៃគាត់នោះ  អាយុក៏ហ្នឹង  ឈ្មោះក៏ហ្នឹង អាសយដ្ឋានក៏ហ្នឹង  ត្រូវគ្នាទាំងអស់  តែគាត់ថា  មានអ្នកបោះរួចហើយ  តែដៃរបស់គាត់អត់ទាន់មានជ្រលក់ថ្នាំទេ  ហើយគាត់ក៏អត់ទាន់បានបោះដែរ នេះជាបញ្ហាមួយ ដែលវាជាបញ្ហាចោទឡើងកន្លងមក ។ **ទី២** ការិយាល័យបោះឆ្នោត និងពេលវេលានៃការបិទការិយាល័យបោះឆ្នោតបើប្រៀបធៀបមកខាង PEC  បានលើកឡើងថាក្នុងមួយការិយាល័យមាន  ៧០០នាក់  ក៏ប៉ុន្តែដោយនីតិវិធីបោះឆ្នោតជាតិ  និងការបោះឆ្នោតក្រុមប្រឹក្សាឃុំ  គឺពេលវេលា  នៃការបោះខុសគ្នា  តែក្នុងមួយការិយាល័យកំនត់  ៧០០នាក់ដូចគ្នា  ។ បោះឆ្នោតជាតិ  គឺកំនត់បិទនៅម៉ោង ៥ល្ងាច ដែលក្នុងមួយការិយាល័យ ៧០០នាក់ដែរ  ដោយឡែកបោះឆ្នោតក្រុមប្រឹក្សាឃុំ  មួយការិយាល័យ  ៧០០នាក់ដូចគ្នា  ក៏ប៉ុន្តែបិទ  នៅម៉ោង៣  ពេលវេលាវាខុសគ្នា  អញ្ចឹងបញ្ហានៃការប្រជ្រៀត ដូចអស់លោកលើកឡើងខាងដើម ការតំរង់ជួរដល់ពេលគាត់ធុញទ្រាន់ទៅ គាត់ត្រឡប់ទៅវិញ ជាក់ស្តែងការបោះឆ្នោតឃុំកន្លងមកការដោះស្រាយនៃពេវេលានេះទាំងគណបក្ស ទាំង គជប គឺប្រជាពលរដ្ឋមិនចាប់អារម្មណ៍ ដែលឃើញមានចំនុចខ្វះខាត អញ្ចឹងគាត់ចាំ ម៉ោង ៤ បានគាត់មកបោះ  ព្រោះគាត់ធ្លាប់បោះឆ្នោតជាតិម៉ោង៥បានបិទ  អញ្ចឹងម៉ោង  ៤ឬ៤កន្លះ  បានគាត់មកហើយនេះជាបញ្ហាមួយដែលគាត់មិនបានបោះឆ្នោះ ។ ដូច្នេះសំនូមពរដលអង្គការមិនមែនរដ្ឋាភិបាល ក៏ដូចជា NEC តើគួរមាននីតិវិធីណា ដើម្បីសំរួលនឹងកែតំរូវឱ្យអស់បញ្ហា ។

**លោកស្រី លីម ដាវី** នាយប្រតិបត្តិនៃអង្គការ CWARO លោកស្រីបានលើកឡើងថាការចុះឈ្មោះបោះឆ្នោតកន្លងមកខាងអង្គការ លោកស្រីបាន  សង្កេតឃើញថាការចុះឈ្មោះបោះឆ្នោត  និងវិធីសាស្ត្រអនុវត្តរបស់មន្ត្រីរៀបចំការបោះឆ្នោតនៅតាមការិយាល័យនីមួយៗគឺមានការខ្វះខាតដូចតទៅ  ។ **ទីមួយ** សង្កេតឃើញថានៅតាមមូលដ្ឋាន មេភូមិ មេឃុំ គាត់បង្កលក្ខណៈងាយស្រួលបំផុតក្នុងមួយថ្ងៃ គាត់ធ្វើប័ណ្ណគ្រួសារឱ្យចុះឈ្មោះបោះឆ្នោតបាននេះតែមួយម៉ោងគត់  ។ **ទី២** គឺអាជ្ញាធរដែនដី  ក៏សូមសំនូមពរដែរថាធ្វើម៉េចឱ្យពិនិត្យប្រជាពលរដ្ឋ  នៅក្នុងភូមិឃុំ  របស់លោកឱ្យបានច្បាស់តាមការសង្កេតកន្លងមកឃើញថាប្រជាពលរដ្ឋនោះ  មិនមែននៅក្នុងភូមិនោះ  ឃុំនោះទេ  ប៉ុន្តែមានប្រជាពលរដ្ឋផ្សេងមកចុះឈ្មោះនៅក្នុងឃុំនោះ  ។ **ទី៣** សូមឱ្យ NEC  រៀបចំរបៀបរៀបរយ  នៅពេលប្រពលរដ្ឋគាត់អញ្ជើញទៅបោះឆ្នោត  ព្រោះកន្លងមក  ឃើញថាមានការរុញច្រានគ្នាហាក់បីដូចជាគ្មានសណ្តាប់ធ្នាប់ ដែលធ្វើឱ្យគាត់មិនអាចឈរទ្រាំនៅរងចាំការបោះឆ្នោតបាន ដូច្នេះជាសំនូមពរ គឺធ្វើយ៉ាងណាឱ្យមាន តុ មានជួរ តាមលេខរៀងឱ្យបានត្រឹមត្រូវ ដើម្បីឱ្យគាត់ ងាយស្រួលចូលរួមការបោះឆ្នោតផង ។ **ទី៤** បានឃើញផ្ទាល់តែម្តង នូវវត្តមានមេភូមិ មេឃុំ នៅជិតការិយាល័យបោះឆ្នោត  តែងតែកើតមានឡើងនៅតាមការិយាល័យក្នុងស្រុកតាខ្មៅ  ក៏ដូចជាក្នុងស្រុកស្អាង  ។ ជាសំនូមពរសូមឱ្យ NEC  ធ្វើយ៉ាងណាផ្សព្វផ្សាយដល់សមាជិកក្រុមការងារទាំងអស់ឱ្យបានយល់ថា  តើមេឃុំគាត់មានសិទ្ធិនៅពេញមួយថ្ងៃឬទេ  នៅជិតការិយាល័យបោះឆ្នោត  ឬ  ក៏គាត់មានសិទ្ធិនៅឆ្ងាយពីការិយាល័យបោះឆ្នោតចំនួនប៉ុន្មានម៉ែត្រ  ១០០ម៉ែត្រ  ឬ៥០ម៉ែត្រ  សូមចែងច្បាប់នោះឱ្យបានច្បាស់  ។ **ទី៥**  ការវេចខ្ចប់របស់មន្ត្រីរៀបចំការបោះឆ្នោត   គឺមានការយឺតយ៉ាវខ្វះជំនាញបច្ចេកទេស   ព្រោះរាប់សន្លឹកឆ្នោតហើយ   បីបួនប្រាំម៉ោងហើយនៅតែរៀបវេចខ្ចប់នៅមិនទាន់ហើយទៀត។ **ទី៦**  ការរលត់ភ្លើងនៅពេលដែលដឹកសន្លឹកឆ្នោតទៅដល់  PEC  សំនូម  ពរដល់  NEC  សូមមេត្តារៀបចំការងារនេះឡើងវិញ  ។ **ទី៧** សូមសំនូមពរទៅ NEC  មេត្តាធ្វើយ៉ាងណាឱ្យប្រព័ន្ធផ្សព្វផ្សាយឱ្យបានដល់មូលដ្ឋាន  ពីព្រោះនៅមូលដ្ឋានគាត់អត់ដឹងថ្ងៃបោះឆ្នោតទេ ព្រោះកន្លងមក NEC ផ្សាយតែនៅថ្នាក់ជាតិ ហើយប្រជាពលរដ្ឋនៅតាមផ្លូវលំ គាត់អត់បានដឹងពតិមាននោះទេ ។

**លោក ឪក សេរី សោភ័ណ្ឌ** បានបញ្ជាក់ប្រាប់អង្គប្រជុំថាដោយយើងមានក្រុមប្រឹក្សាឃុំ-សង្កាត់   ដែលមកពីគណបក្សទាំង  ៣  មានអង្គការសង្គមស៊ីវិលធ្វើការ   ដូច្នេះលោកគិតថាព័តិមានដែលបានចែកចាយទៅដល់ថ្នាក់មូលដ្ឋាននៅមានខ្វះចន្លោះច្រើន   ដែលយើងទាំងអស់គ្នាត្រូវ

តែចូលរួមសហប្រតិបត្តិការគ្នាតាំងពីឥឡូវហ្នឹងទៅ។ មួយវិញទៀត តាំងពីដំណើរការធ្វើខប់សែលឆ្នាំ១៩៩៩ មកដល់ឥឡូវនេះ យើងនៅតែឮសូរនូវបញ្ហាពតិមាន ចែកចាយមិនឮដល់ប្រជាពលរដ្ឋ ។ ដូច្នេះសង្ឃឹមថាយើងនិងមានចលនារួមគ្នា ដើម្បីបញ្ចប់ឱ្យបាននូវបញ្ហានេះក្នុងរយៈពេល ៣ ឆ្នាំខាងមុននេះ ហើយជាការមួយល្អប្រសើរណាស់ប្រសិនជាយើងអាចរួមកំលាំងគ្នា តាំងពីអាជ្ញាធរមូលដ្ឋាន ថ្នាក់លើរហូតដល់ថ្នាក់ក្រោម គណបក្សទាំង ៣ ហើយ ជ្រៀតចូលទៅដល់ក្រុមប្រឹក្សាឃុំ-សង្កាត់ទៀត ហើយអង្គការសង្គមស៊ីវិល ខាងសីលាបានដាក់គ្នាចុះទៅទៀត យើងគិតថាបញ្ហាហ្នឹងគួរតែលែងមានទៀតហើយក្នុងរយៈពេល ៣ឆ្នាំខាងមុខនេះ ។

**លោក តុលប្រាសាទ** បានបំភ្លឺទៅលើប្រសាសន៍របស់លោកមេឃុំ ស្វាយប្រទាល សូមឱ្យលោកជ្រាបថា សំដីដែលលោកបាននិយាយកន្លងទៅនេះ មិនបាននិយាយចោទប្រកាន់ទៅលើគណបក្សនយោបាយណាមួយទេ គឺគ្រាន់ជំរាបថា រឿងកន្លងហួស គឺសូមឱ្យយើងទាំងអស់គ្នា ទាំងគណបក្សនយោបាយ ទាំង គជប និងអាជ្ញាធរទាំងអស់ ត្រូវគោរពច្បាប់ គោរពរដ្ឋធម្មនុញ្ញ គោរព ច្បាប់បោះឆ្នោត ចាប់ពីការបោះឆ្នោតក្រោយៗទៀត ។

**លោក គឹម ហុង** ក្នុងនាម PEC លោកបានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះវាគ្មិនទាំងអស់ដែលបានចូលរួមយោបល់អនុសាសន៍ដែលបង្ហាញពីកង្វះខាតមួយចំនួន ដែលការងារបោះឆ្នោតបានប្រព្រឹត្តកន្លងផុតទៅ ។ លោកបន្តទៀតថាការប្រជុំព្រឹកនេះ ពិតជាមានសារៈសំខាន់ណាស់ ដែលការចូលរួមមានគ្រប់គណបក្សទាំង៣ គណបក្សសម រង្ស៊ី គណបក្សហ្វ៊ុនស៊ិនប៉ិច គណបក្សប្រជាជន អាជ្ញាធរឃុំ ស្រុក និងអង្គការសង្គមស៊ីវិល ។ ជុំវិញការបើកយុទ្ធនាការឃោសនា តាមច្បាប់ មុននឹងធ្វើពិធីក្រៅពីទីស្នាក់ការផ្ទាល់របស់ខ្លួន គណបក្សនីមួយៗត្រូវតែជូនដំណឹងដល់ PEC ធ្វើអន្តរាគមន៍ទៅតាមទីកន្លែងនោះ ឱ្យអាជ្ញាធរ បញ្ជាការឯកភាពស្រុក ឃុំ ចាត់វិធានការការពារ ឫសំរួល ប៉ុន្តែភាគច្រើនយើងមិនសូវបានទទួលសេចក្តីជូនដំណឹងទេ ស្រាប់តែឮថាធ្វើតែម្តង ហើយមានបញ្ហា ។

លោកមិនបានឆ្លើយតបរាល់សំណួរវាគ្មិនទាំងអស់ទេ គឺយកតែបញ្ហាណាដែលចោទលើគ្នា យើងឆ្លើយតែម្តង ហើយចំនុចណាដែលឆ្លើយមិនទាន់បាន លោកកត់ត្រាទុកយកទៅឆ្លងយោបល់ថ្នាក់លើទៀត ។ ចំងល់ទាំងអស់ គឺជុំវិញការបើកយុទ្ធនាការឃោសនា ដូចថា គណបក្សខ្លះថាហាក់ដូចជាប្រកាន់គណបក្សនយោបាយ គឺគណបក្សកាន់អំណាចធ្វើការឃោសនាហែរក្បួន ឬក៏ប្រជុំគឺមាន ប៉ូលីសទៅហែរហ៊ម ទៅបើកផ្លូវ តែគណបក្សគាត់មិនមាន លេកបញ្ជាក់ជូនថា PEC ត្រៀមខ្លួនឱ្យរហូត តាមច្បាប់ឃោសនា មុននឹងធ្វើពិធីធំដុំ ក្រៅពីទីស្នាក់ការផ្ទាល់ គណបក្សនីមួយៗ ត្រូវតែជូនដំណឹងមិនឱ្យសុំទេ គ្រាន់តែជូនដំណឹងដល់ PEC ដើម្បីធ្វើអន្តរាគមន៍ទៅតាមទីកន្លែងនោះ ដើម្បីឱ្យអាជ្ញាធរ ដូចជា គណៈបញ្ជាការឯកភាពស្រុក ឃុំ ចាត់វិធានការ ការពារ ឫសំរួល ប៉ុន្តែភាគច្រើនយើងខ្ញុំមិនសូវបានទទួលសេចក្តីជូនដំណឹងទេ ស្រាប់តែឮថាធ្វើតែម្តង ហើយមានបញ្ហា ។ បញ្ហាទីកន្លែងមិនមែនជាសិទ្ធិអំណាចរបស់ PEC ទេ ជាសិទ្ធិអំណាចរបស់ម្ចាស់ដែលគ្រប់គ្រងទីកន្លែង គឺសាម៉ីគណបក្សត្រូវសុំការយល់ព្រមជាមុនអំពីសាម៉ីគ្រប់គ្រងទីកន្លែង ដូចជា ទីធ្លាសាលារៀន វត្តអារាម ឬទីតារាងបាល់ ឬក៏ទីកន្លែងណា បើម្ចាស់គេយល់ព្រម ជូនដំណឹងថាបានសុំកន្លែងនេះបានហើយ លោកធ្វើសំណើសុំទៅគណៈបញ្ជាការឯកភាព ដើម្បីមានវិធានការជួយសំរួលការ ការពារសន្តាប់ធ្នាប់ ។ បញ្ហាយុទ្ធនាការមិនមែនថា PEC អនុញ្ញាតឱ្យកន្លែងនេះកន្លែងនោះទេ PEC គ្មានសិទ្ធិទេ ព្រោះមានម្ចាស់គ្រប់គ្រង អញ្ចឹងត្រូវមានទំនាក់ទំនងល្អជាមួយម្ចាស់មូលដ្ឋាន វត្តទាក់ទងជាមួយចៅអធិការ អាចារ្យវត្ត ឬគណៈកម្មាធិការវត្ត សាលារៀនទាក់ទងជាមួយនាយកសាលា ទីលានតារាងបាល់ ត្រូវទាក់ទងនរណាគ្រប់គ្រងតារាង បើមិនអញ្ចឹងយើងជួលកន្លែងណា ស្រេចតែអស់លោក រោងកុនក្តី រោងប្រជុំណាមួយក្តី នេះវាជាសិទ្ធិជាលទ្ធភាពរបស់គណបក្សនីមួយៗ ។

អំពីការចុះឈ្មោះដោយប្រើរូបថត ខ្ញុំបានជំរាបរួចហើយថា ពីឆ្នាំណាដល់ឆ្នាំណា វាពិបាករបៀបម៉េច ប៉ុន្តែដល់ឥឡូវដំណាក់កាលឆ្នាំ២០០៤ ដល់ឆ្នាំ២០០៥ នេះ យើងកាត់បន្ថយ ។ បញ្ហារូបថតមិនតំរូវចាំបាច់ ត្រូវតែមានទេ បើមានរឹតតែល្អ តែបើគ្មានលទ្ធភាព យើងអាចចុះឈ្មោះបានដូចគ្នាដែរ គឺសង្ឃឹមថា ដល់ឆ្នាំ២០០៧ នេះ អ្នកដែលមានអាយុ ១៨ឆ្នាំឡើងលើ គឺអាចនឹងមានអត្តសញ្ញាណប័ណ្ណ ហើយតាមការសន្យារបស់ខេត្តនីមួយៗ យើងមានច្រកចេញមួយទៀត គឺធ្វើតែទំរង់ ១០១៨ ជាច្រកសំរួលជូន ។

រីឯសំនូមពរឱ្យមានរូបថតឡើងវិញល្អហើយ លោកក៏ចង់បានវិញដែរ ប៉ុន្តែវាអាចមានផលវិបាកដល់ការជ្រើសរើសអ្នកកាន់ម៉ាស៊ីនថតនេះ ជួនកាលមួយឃុំ រកអ្នកចេះកាន់ម៉ាស៊ីនថតនោះ ពិបាកណាស់ ជួនកាលម៉ាស៊ីនថតគេល្អ ចុចចុះចុចឡើង ខូចម៉ាស៊ីនថត ប្រជាពលរដ្ឋមកថតឈរចាំស្ទះ ឥឡូវបានកាត់បន្ថយ មិនចាំបាច់ទេរូបថត ចាំដល់ពេលថ្ងៃបោះឆ្នោតចាំគិតទៀត ។

ការឱ្យជំនួយការម្នាក់ ឬពីរនាក់តាមលទ្ធភាពឃុំធំតូច ឥឡូវយើងផ្តាច់ជំនួយការឱ្យនៅតែស្មៀនម្នាក់ឯង ដំបូងទី គាត់មិនទាន់យល់ដឹងច្បាស់ពីការងារចុះឈ្មោះ ហើយឥឡូវគាត់ដកពិសោធន៏ ១-២ឆ្នាំហើយ បានជាយើងមិនផ្តល់ជំនួយការ ។ ម្យ៉ាងទៀតបញ្ហាថវិកា ដូចបានជំរាបជូនអញ្ចឹង ចេះតែរួញទៅៗ ម្ល៉ោះហើយអ្វីដែលចាំបាច់បំផុតទើបប្រើប្រាស់ កាលណាអាចសំរបសំរួលបាន ក៏ចេះតែកាត់បន្ថយអញ្ចឹងដែរ ។ PEC ពីដើមមាន ៥៤នាក់ បោះឆ្នោតក្រោយមក ចុះមកនៅត្រឹម ៤០នាក់ ដល់បោះឆ្នោតមួយថ្ងៃនោះតែ ៨នាក់ទេ ទាំងអ្នកបើកឡានផង ។

រឿងចងបាដារ អាយ៉ៃឆ្លើយឆ្លងគ្នា អត់មានបញ្ហាអីទេ បញ្ហាលើកផ្លាកគណបក្សនេះ ធាតុពិតត្រូវតែសុំការអនុញ្ញាតពីមូលដ្ឋាន ហើយមានតែម្ចាស់មូលដ្ឋានទេទើបដឹងកន្លែងណា គេធ្លាប់ដឹង គ្រាន់តែថា បើផ្លាកសញ្ញាគេមានតាំងពីយូរហើយ ទោះបីវានៅជិតទីស្នាក់ការបោះឆ្នោតរបស់ CEC ក៏ដោយ អត់ឱ្យរើទេ ផ្លាកកើតមុនទីស្នាក់ការ CEC ។ រឿងលោកប្រធានភូមិ ឃុំ នៅជិតការិយាល័យបោះឆ្នោត ដូចបានជំរាបជូនហើយ ទីមួយ គាត់ក៏ជាប្រជាពលរដ្ឋ ម្នាក់ដែលត្រូវទៅបោះឆ្នោតដែរ អញ្ចឹងគាត់ទៅឈរជាជួរ ទីពីរ គាត់អាចសំរួលដល់អ្នកងងឹតភ្នែក អ្នកមិនចេះអក្សរ ក៏អាចមានគណបក្ស ខ្លះចោទថាខ្សិបខ្សាវអញ្ចេះអញ្ចុះ បានជាចេះតែនៅទីនេះមិនព្រមចេញ ។ ដំណាក់កាលនេះមនុស្សកាន់តែយល់ច្រើនហើយអំពីការងារបោះឆ្នោត ដើម្បីដោះស្រាយបញ្ហានេះ ក្រសួងមហាផ្ទៃបានចេញលិខិតមួយ ក៏ដូច គជប បានណែនាំមេភូមិ កុំឱ្យទៅក្បែរស្ថានីយបោះឆ្នោតតែម្តង ។ នេះជាការ យោគយល់ដែរ លោកជឿថា មិនអាចទៅបញ្ចេះប្រជាពលរដ្ឋថា គូសលេខរៀងនេះ លេខរៀងនោះទេ ។ ចំពោះអង្គការមិនមែនរដ្ឋាភិបាលដែលធ្វើសកម្មភាពនៅក្នុងឃុំ ត្រូវជំរាបឃុំផង កុំឱ្យមានការភ្ញាក់ផ្អើល គ្រាន់តែជំរាបគាត់មួយម៉ាត់ គាត់មិនជំទាស់ទេ ដោយសារអង្គការនេះមានភារកិច្ចក្នុងការជួយជំរុញការងារបោះឆ្នោត ។ ប៉ុន្តែពេលគាត់មិនជំរាបមេឃុំ បានជាមេឃុំ ចោទប្រកាន់ ។

សំខាន់មួយដែរ ការចាត់ភ្នាក់ងារឱ្យទៅសង្កេតការបោះឆ្នោត លោកបានសំណូមពរគ្រប់គណបក្សទាំងអស់ ពេលបញ្ជូនភ្នាក់ងារទៅសង្កេតការបោះឆ្នោត គឺទីមួយត្រូវឱ្យចេះនីតិវិធី ឱ្យដឹងច្បាប់ទំលាប់ បទបញ្ជាច្បាស់លាស់ ។ ទីពីរត្រូវតែមានសេចក្តីក្លាហានថា ទៅហើយត្រូវចុះហត្ថលេខាឱ្យគេផង ព្រោះជួនកាល គេធ្វើហើយ សុំហត្ថលេខាជាសាក្សី គាត់ដើរចេញបាត់ អត់ចុះហត្ថលេខា ដូចជាការបោះឆ្នោតព្រឹទ្ធសភា លោកហៅគ្រប់គណបក្សទាំងអស់ ទាំងអ្នកសង្កេតការណ៏ទៅបង្រៀន ទើបទទួលបានលទ្ធផលល្អ។ សន្លឹកឆ្នោតបានការ និងមិនបានការ ដូចជាមានតិចតួច វាមិនសូវមានបញ្ហាប៉ុន្មានទេ ដូចជាបំរាមលើកនេះហាមថា សូម្បីតែស្ទីឡូ ដែលយើងប្រើពីដើមមានទឹកខ្មៅ ក៏ហាមមិនឱ្យគូសដែរ ។

បញ្ហាសំនូមពររបស់ខាងក្រុមប្រឹក្សាឃុំតាខ្មៅ គាត់ចង់បាន សមាភាពស្ត្រីច្រើននៅក្នុងជួរគណៈកម្មាធិការបោះឆ្នោត បើខ្ញុំសង្កេតមើល នៅ PEC ក៏មានដែរ មានមិនដល់ ៥០% ក៏ខ្ទង់ ៣០% ដែរ ជាស្ត្រី ជាពិសេសគ្រូបង្ហាត់តាមមូលដ្ឋាននោះ ភាគច្រើនជាស្ត្រី ហើយបើ CEC វិញក៏មានស្ត្រីដែរ បើ CEC នៅតាខ្មៅវិញ ស្ត្រីទាំងអស់មានតែប្រធានម្នាក់ទេ ប្រុស ៥នាក់ ស្រី ៤នាក់ ។ បើនៅការិយាល័យបោះឆ្នោតវិញ មន្ត្រីការិយាល័យបោះឆ្នោត ដែលយើងហៅថា PSO សុទ្ធតែមានស្ត្រីមិនអត់ទេ នេះវាមិនបញ្ហា ទេ។ បញ្ហាដែលថាចង់ឱ្យមន្ត្រីបោះឆ្នោត បង្រៀនយុវជនទាំងអស់គ្នាឱ្យយល់ដឹងពីសន្លឹកឆ្នោតបានការ និងមិនបានការ នេះវាក្តោបធំពេក ដូច្នេះយើង ហៅតែប្រធានគណបក្សនានា និងអង្គការមិនមែនរដ្ឋាភិបាលទៅណែនាំ

ដែលរឿងនេះ យើងធ្វើការប្រជុំសឹងតែរាល់សប្តាហ៏ ដោយមានអ្នកចូល រួមមកពីតំណាងគណបក្សនយោបាយទាំងបី អភិបាលខេត្ត អភិបាលរងទី១ ខេត្ត អភិបាលស្រុក ដែលការណែនាំនេះ វាអាចផ្តាំផ្ញើតាមគណបក្ស ហើយគណបក្សទៅតាមសកម្មជនរបស់ខ្លួនបន្តទៀត ។

បញ្ហាចង់ឱ្យការចុះឈ្មោះមានប័ណ្ណសាជាថ្មីឡើងវិញ ដោយសំអាងថា ឥឡូវនេះសឹងតែមិនបាច់បានទេ គ្រាន់តែចេញចុងសន្លឹកចុះសំគាល់ថាបានចុះឈ្មោះហើយ ប៉ុន្តែដល់ថ្ងៃបោះឆ្នោតឆ្នាំ២០០៧ ប្រាកដជាមានអត្តសញ្ញាណប័ណ្ណ ដូច្នេះប័ណ្ណក៏លែងត្រូវការដែរ ដូច្នេះជាដំណោះស្រាយមួយហើយ ។ រឿងមេឃុំមិននៅ មិនផ្ទេរសិទ្ធិឱ្យជំទប់ លោកបានណែនាំដែរ តែដល់ផ្ទៃក្នុងលោកមិនលូកដៃចូលទេ សូមមេត្តាបង្កសាមគ្គីភាពផ្ទៃក្នុងចុះ ជាពិសេសលោកអភិបាល អភិបាលរងស្រុក លោកអញ្ជើញផ្ទាល់ លោកស្តាប់ទៅ នេះវាហួសពីសមត្ថកិច្ច ប៉ុន្តែលិខិតណែនាំ របស់ គជប មានគ្រប់ករណីទាំងអស់ ក្នុងករណីណាដែលមេឃុំជាប់រវល់ទៅណា សូមឱ្យផ្ទេរសិទ្ធិមាន។ ប៉ុន្តែរឿងនេះវាដោយឡែករបស់មេឃុំទេ មេឃុំខ្លះ គេផ្ទេរត្រឹមត្រូវ មានខ្លះដែរ ដែលមិនគោរពតាមលិខិតណែនាំ ហើយលោកក៏មិនហ៊ានអះអាងដែរ ទុកគ្រាន់ជាមេរៀនមួយសំរាប់យើងយកទៅពិចារណាទាំងអស់គ្នា។ រឿងសំបុត្រកំណើតក្លែងក្លាយ មិនក្លែងក្លាយ លោកមិនឆ្លើយទេ ព្រោះហួសពីភារកិច្ច លោកមិនដែលដឹង ទើបនឹងដឹងថ្ងៃនេះ ។ ការចុះឈ្មោះនៅតាមការិយាល័យចល័ត ដល់ចុះទៅចល័ត មេឃុំមិនទៅតាម ឱ្យប្រជាជនមកសុំនេះសុំនោះវាពិបាក នេះមានមួយៗមែន ហើយជួនកាលក៏អាចមានអញ្ចឹងដែរ ហើយបើគាត់មានឯកសារទៅហើយ មេឃុំមិនបាច់ទៅទេ ស្មៀនគេសំរេចបានហើយ លើកលែងតែទៅដល់ខ្វះឯកសារត្រូវមកសុំឱ្យមេឃុំបំពេញ អាចមានមែន ប៉ុន្តែនេះជារឿងរបស់ CEC លោកមេត្តាជួយសំរួលបញ្ហានេះផង ។

សុំឱ្យបង្កើតស្ថាប័នឯករាជ្យមួយសំរាប់ចុះឈ្មោះ ហួសសមត្ថភាព មិនដឹងថាឱ្យនរណាឯករាជ្យទៀតទេ ព្រោះគ្មាននរណា ដែលគ្មានទស្សនៈគណបក្សនយោបាយនោះទេ ដូចសម្តេចនាយក លោកថា ទេព្តាចុះមកពីណាមក គ្មាននរណាទៅរកមនុស្សណាគ្មានទស្សនៈនយោបាយបានទេ ។ អាចប៉ះពាល់ថវិកាផង វាអាចប៉ះពាល់រចនាសម្ព័ន្ធផង ព្រោះកន្លងមកវាគ្មាន ។ មួយវិញទៀត ការសុំឱ្យមានមន្ត្រី PEC ម្នាក់ចាំមើលឈ្មោះឱ្យ ប្រជាជនក៏វាហួសពីលទ្ធភាពដែរ ព្រោះគេឱ្យតែមួយឃុំ ៥នាក់ មួយ CEC ៥នាក់ ហើយមួយការិយាល័យតែ ៥នាក់ ហើយបើដកម្នាក់ឱ្យចាំតែមក មើលឈ្មោះក៏ពិបាកដែរ ។ ដូច្នេះមានតែគណបក្សនយោបាយ និងសកម្មជន ណែនាំប្រជាពលរដ្ឋ ឱ្យមកមើលឈ្មោះឱ្យហើយ ការដែលគេបិទបញ្ជីចុង ក្រោយ ឬបញ្ជីផ្លូវការហើយបើគេសួរអាចប្រាប់ តែបើឱ្យបង្កើតមនុស្សម្នាក់ទៀតចាំមើលតែឈ្មោះសំរាប់ គជប ក៏ពុំមានលទ្ធភាពដែរបើតាមស្ថានមើលទៅ ។ រឿងប្រជាជនដែលទៅបោះឆ្នោតរុញច្រានគ្នានេះ មិនមែនតែប្រជាជនទេ ថ្ងៃមួយនោះ លោកឡើងលើតុ ជំទៀលខ្លួនឯង ព្រោះជួនកាលមានសំពាធមនុស្សច្រើនជួនកាលប្រញាប់ ជាពិសេសពីរនាទីចុងក្រោយ នៃការបោះឆ្នោត។ ការរេចខ្ចប់មានការ យឺតយ៉ាវ លោកនឹងព្យាយាមទៅបំប៉នមន្ត្រី គជប ខេត្ត ថែមទៀត ដើម្បីឱ្យកាន់តែមានលទ្ធភាព ។ រឿង ពេលដឹកហឹបឆ្នោតទៅដល់ PEC រលត់ភ្លើង ឥឡូវមិនមែនដូចសម័យអ៊ុនតាក់ ដឹកឡានកាណូត ទូក យន្តហោះមករាប់មួយកន្លែងនៅខេត្តនោះទេ ឥឡូវបោះទីណារាប់ទីនោះ ពេលដែលដឹកមក PEC គឺគេដឹងលទ្ធផលអស់ហើយ ដូច្នេះក៏មិនបញ្ហាចោទទេ ព្រោះរាប់នៅការិយាល័យបោះឆ្នោតរួចហើយ ។ គណបក្សទទួលស្គាល់កត់ដឹងឮ ឬក៏បាន ទទួលទំរង់ ១១.០៩ រួចអស់ហើយគាត់លែងចង់ឆ្ងល់អីទៀតហើយ ស្រាប់តែដឹកមក PEC ដឹកថ្ងៃ មិនមែនដឹកយប់ ដឹកពេលព្រឹកឡើង ជួនកាលដឹកមកដល់ម៉ោង ១២ រឺ ១ ដូច្នេះមិនចោទទេ ហើយយើងក៏បានត្រៀមជួលផងដែរ នូវម៉ាស៊ីនភ្លើងពីរនៅទីនោះ PEC ក្រែងរាប់ទៅយប់ពេក មួយ ទៀត ក្រែងលោដឹកទៅទាំងយប់ គេសង្ស័យអញ្ចេះអញ្ចុះ ។ កន្លងទៅគណបក្សនយោបាយលោកដឹងពតិមាន លោកកត់ខ្លួនឯងផង មន្ត្រីរៀបចំបោះ ឆ្នោត ប្រគល់ជូនទំរង់ ១១០៩ រួចរាល់អស់ហើយ។ លោកបានបន្តថា នេះគឺជាការបំភ្លឺបកស្រាយខ្លះ ទោះបីជាសមស្រប ឬក៏សមចំនុចត្រូវចិត្តក្តី ឬមិនទាន់ពេញចិត្តក្តី សូមអធ្យាស្រ័យ ព្រោះនេះជាការបកស្រាយរួម ព្រោះជួនកាលអាចខ្វះចន្លោះដែរ។

**លោក ឌិក សេរី សោភក្តិ៏** តាងនាមឱ្យវិទ្យាស្ថាន CDRI បានថ្លែងនូវអំណរគុណយ៉ាងជ្រាលជ្រៅដល់សមាជិកនៃអង្គប្រជុំ ដែលបានចូលរួមយោបល់ដ៏មានសារៈប្រយោជន៏ ហើយក៏សូមអរគុណដល់ លោកប្រធាន PEC ដែលលោកបានឆ្លើយបំភ្លឺចំណុចស្ទើរតែទាំងអស់ ដោយក្បោះ

ក្បាយ និងដោយលំអិត ។ សាជាថ្មីម្តងទៀត សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះអាជ្ញាធរខេត្ត ដែលមាន **ឯកឧត្តម ឡៅ ស៊ុនប៉ា** ជាអភិបាលខេត្ត បានបើកទ្វារឱ្យយើងមានការជជែកពិភាក្សាគ្នាយ៉ាងល្អនេះ ។ ខ្លឹមសារសង្ខេបនៃកិច្ចពិភាក្សាក្នុងកិច្ចប្រជុំ មានដូចតទៅៈ

ទី១. បានស្តាប់ ការបង្ហាញលំអិតអំពី សភាពការណ៍បោះឆ្នោតទូទៅរបស់ព្រះរាជាណាចក្រកម្ពុជារបស់ប្រធាន PEC ។

ទី២. លោកបាននិយាយលំអិតផងដែរអំពី សភាពការណ៍នៃការ រៀបចំការបោះឆ្នោតមកដល់ថ្ងៃនេះ ហើយនិងការប្រមើលមើលទៅថ្ងៃក្រោយនៅក្នុងខេត្តកណ្តាលរបស់យើងផ្ទាល់តែម្តង ។

ទី៣. ទាក់ទងទៅនឹង ពតិមានដែលអង្គប្រជុំ វាគ្មិនច្រើនណាស់បានលើកឡើងមានសំនូមពរសូមឱ្យចលនាទាំងអស់គ្នា ទាំគណបក្សនយោបាយ ទាំងអាជ្ញាធរមូលដ្ឋាន ទាំងសង្គមស៊ីវិល PEC, CEC ឱ្យរួមគ្នាធ្វើសហប្រតិបត្តិការ ដើម្បីនឹងជួយចែកជូនពតិមាននេះ ឱ្យបានទៅដល់បងប្អូនប្រជាពលរដ្ឋ នៅថ្នាក់ភូមិ ។

ទី៤. យើងប្រមើលមើលទៅលទ្ធផលដែលបានទទួលនៅក្នុងការចុះឈ្មោះបោះឆ្នោតនៅខេត្តកណ្តាលនេះ  ប្រហែលជាយើងអាចបានលទ្ធផលក្បែរនឹង ១០០% នៅចុងឆ្នាំ២០០៦ ដើម្បីនឹងត្រៀមបោះឆ្នោតក្រុមប្រឹក្សាឃុំសង្កាត់នៅប្រហែលជាខែកុម្ភៈ ឆ្នាំ២០០៧ ឬ ក៏ខែមេសា តាមដែលយើងបានពិភាក្សាជាមួយ NEC ។

ទី៥. យុទ្ធនាការឃោសនាបោះឆ្នោត យើងគិតថា បញ្ហានេះបានលើកច្រើនណាស់ ពីព្រឹកមិញ ក៏ប៉ុន្តែនៅតែមួយ គឺបើសិនជាគណបក្សទាំងអស់ដែល ចូលរួមធ្វើយុទ្ធនាការឃោសនាបោះឆ្នោត គោរពនីតិវិធី និងគោលការណ៍ ក្រមសីលធមិឱ្យបានច្បាស់លាស់ នោះប្រហែលជាអាចបានជួយដោះស្រាយ បញ្ហាយ៉ាងមានប្រសិទ្ធភាព ។

ទី៦. បញ្ហាដែលមានអាជ្ញាធរថ្នាក់មូលដ្ឋាន ដូចជាមេឃុំទៅឈរ ឬ អាជ្ញាធរផ្សេងៗទៀតទៅឈរនៅក្បែរ ការិយាល័យបោះឆ្នោត ក្រសួងមហាផ្ទៃក៏បានណែនាំរួចមកហើយ ហើយប្រធាន PEC ក៏បានមានប្រសាទ៍ ណែនាំទៀតដែរ ហើយយើងគិតថា មិនជានាំឱ្យមានការផ្លាស់ប្តូរលទ្ធផលប៉ុន្មានទេ ដូច្នេះបើសិនជាចំនុចហ្នឹងមិនមានឥទ្ធិពលខ្លាំងក្លាទៅលើយន្តការ នៃការបោះឆ្នោតទេ ហើយខេត្តឯទៀតៗ ក៏បានលើកឡើងដូចគ្នាដែរ ចំនុចនោះយើង គួរតែបំបាត់ទៅ ព្រោះនៅពេលដែលអ្នកសង្កេតការណ៍ អន្តរជាតិទៅឈរមើលឃើញចំណុចដែរមិនបានផលអីសោះប៉ុន្តែបានជាចំនុចអវិជ្ជមាន យើង មិនគួរធ្វើតទៅទៀតទេ ពីព្រោះយន្តការរបស់យើង ល្មមអាចទុកចិត្តបានហើយ ។

ទី៧. គឺបញ្ហាចុះឈ្មោះបោះឆ្នោតនេះ ដែលទាក់ទងទៅនឹងក្រុមប្រឹក្សាឃុំសង្កាត់ ជាពិសេសស្មៀន ។ ស្មៀនឃុំកន្លែងខ្លះ ក៏អាចធ្វើបាន កន្លែងខ្លះទៀត ក៏គាត់មិនមានជំនួយគ្រប់គ្រាន់ បើយើងប្រើប្រាស់៥ខែ នៃការចុះឈ្មោះត្រៀមឱ្យបានត្រឹមត្រូវ នោះដល់ ២០ថ្ងៃនៃខែតុលា គឺស្មៀនឃុំរយាល មិនមានការប្រញាប់ពេកទេ នេះវាស៊ីសងថាតើយើងគ្រប់គ្រងពេលវេលានេះយ៉ាងណា បូកទាំង៥ខែ ត្រៀមហើយហ្នឹង ១ខែចុងក្រោយនេះជាការរួម សហប្រត្តិបត្តការជាមួយគ្នា ដើម្បីដោះស្រាយបញ្ហានេះ ជួយដល់ស្មៀនឃុំសង្កាត់ផងដែរ ។

ទី៨. ដូចជារឿងគណបក្សលើកផ្លាក អាជ្ញាធរទៅហាមឃាត់ ។ បញ្ហានេះ ជាបញ្ហាគោរពដល់នីតិវិធីក្រឹត្យក្រម និងក្រមសីលធមិទេ ដូច្នេះបើសិនជាយើងអនុវត្តឱ្យបានពេញ តទៅនោះការទាំងអស់នេះ មិនគួរចោទជាបញ្ហាកើតឡើងទេ ។

ទី៩. មានស្នើសុំដោយសារ យន្តការឧប់សែលនេះ ជាយន្តការដែលប្រពឹត្តទៅល្អ សុំឱ្យថា ធ្វើយ៉ាងណាដើម្បីចុះឱ្យជ្រៅទៀតដល់មូលដ្ឋានផ្ទាល់តែម្តង ក្រោមថ្នាក់ខេត្តនេះ ទៅទៀតដើម្បីលើកស្ទួយនូវវប្បធមិនៃការជជែកពិភាក្សាគ្នា វិទ្យាស្ថាន CDRI ទទួលសំណើនេះ ហើយនឹងទៅពិភាក្សាជាមួយ UNDP ដើម្បីពិនិត្យមើលលទ្ធភាពថាតើអាចធ្វើបានដល់កំរិតណា ។

ទី១០. បញ្ហាអត្តសញ្ញាណប័ណ្ណ បញ្ហានេះយើងគិតថា ដោយមានសហការពីខាង នគរបាលជាតិ ហើយជាពិសេសពីចៅហ្វាយខេត្តទាំងអស់ដែលឧប់សែល បានចុះទៅដល់ ប្រហែលជាក្នុង ៣ឆ្នាំខាងមុខ ជាពិសេសប្រហែលជាក្នុង ឆ្នាំនេះ យើងអាចឈានទៅដល់កំរិតមួយដែរអាចទទួលយកបាន ហើយគិតថា ៣ឆ្នាំ ប្រជាពលរដ្ឋខ្មែរដែលមានអាយុ ១៨ឆ្នាំ អាចនឹងបានទទួល អត្តសញ្ញាណប័ណ្ណជាតិនេះគ្រប់ៗគ្នា ហើយដែល

យើងអាចប្រើជាកាត សំរាប់យកទៅបោះឆ្នោតក្នុងពេលតែមួយបានផងដោយមិនចាំបាច់មានកាត របៀបអ៊ុនតាក់ កាលជំនាន់ឆ្នាំ១៩៩៣ ទៀតទេ នេះយើងខំប្រឹង ដើម្បីធ្វើ ឱ្យបានយ៉ាងនេះ ។

ទី១១. នៅពេលដែលមានយុទ្ធនាការ ឃោសនាបោះឆ្នោត ដើម្បីជៀសវាងការប្រឈមមុខដាក់គ្នារវាងគណបក្សទៅនឹងគណបក្សដែលចូលរួមក្នុងយុទ្ធនាការឃោសនាបោះឆ្នោត គួរតែមាន ការអនុវត្តនូវក្រមសីលធម៌ ឱ្យបានគ្រប់ជ្រុងជ្រោយទាំងអស់ ហើយដូចដែល PEC, SEC លើកហើយ ការជួបប្រជុំគ្នាដើម្បីបកស្រាយ អោយត្រូវគ្នាអំពីក្រមសីលធម៌ ហើយនិងក្រឹត្យក្រមទាំងប៉ុន្មានហ្នឹង ជាការសំខាន់ណាស់ដើម្បីបង្ការទំនាស់ ឱ្យមាន ការយោគយល់គ្នា ។

ទី១២. កន្លែងនេះខេត្តឯទៀតៗក៏បានលើកដែរ គឺរឿងសំបុត្រកំណើតក្លែងក្លាយហើយបងប្រធាន PEC នៅទីនេះ លោកមិនសួរបានឮខ្ញុំក៏ភ្ញាក់ដែរនៅខេត្តកណ្តាល ប៉ុន្តែខេត្តឯទៀតៗមានបន្លំសំបុត្រកំណើតក្លែងក្លាយ ដើម្បីនឹងដូរអាយុ ឱ្យបានចុះឈ្មោះនៅក្នុងនេះ ហើយមានជនបរទេសខ្លះ ក៏មានកាន់សំបុត្រកំណើតក្លែងក្លាយដែរ នេះបើសិនជាមានករណីហ្នឹង យើងត្រូវពិនិត្យមើលឱ្យបានច្បាស់លាស់ ហើយបញ្ចប់ទៅ កុំឱ្យមានទៀត ។ បញ្ហា ស្ថាប័នឯករាជ្យសំរាប់ចុះឈ្មោះបោះឆ្នោត ខ្ញុំបាទគិត ខ្ញុំយល់ ស្របជាមួយប្រធាន PEC ។

ទី១៣. យើងមិនចាំបាច់មានទេ ព្រោះបើសិនជា យើងមានកាត បើសិនជាយើងគ្រប់គ្រង ពេលវេលាចុះឈ្មោះត្រៀម ៩ខែ ឱ្យបានច្បាស់លាស់ យើងសហការគ្នា ចលនាប្រជាពលរដ្ឋឱ្យបានគ្រប់ ជ្រុងជ្រោយទៅ បើប្រៀបធៀបទៅនឹងអ្វីដែលនៅសេសសល់ ព្រោះយើងចុះឈ្មោះមួយខែៗបាន ៩២-៩៣% ហើយនៅសល់តែ ៧-៨% ទៀតទេ ។ ប្រៀបធៀបនឹងលុយកាក់ ដែលចាយដើម្បីជ្រើសរើសមនុស្សដែលយើងហៅថាឯករាជ្យនោះឱ្យមកធ្វើ ជាស្ថាប័ន នេះខ្ញុំគិតថាមិនគួរចំនាយទេ យើងខំប្រឹងធ្វើការជាមួយគ្នាដោយចំហរទៅ សុទ្ធតែបញ្ហាដែលយើងអាចដោះស្រាយបានទេនៅក្នុងរឿង ទាំងអស់នេះ ព្រោះយើងមិនមានថវិកា ឯណានឹងទៅចំនាយ ហើយទៅរកស្ថាប័នណាដែលឯករាជ្យ ក៏ពិបាករកដែរ នៅក្នុងស្ថានការណ៍សព្វថ្ងៃនេះ ដូចច្នេះបញ្ហានេះនឹងពិចារណាមើល ។

ទី១៤. នេះជាបញ្ហាដែលបានលើកឡើង ហើយខេត្តខ្លះទៀត ក៏បានលើកឡើងដែរ ប៉ុន្តែយើងគិតថា បញ្ជីឈ្មោះអាចនឹងដោះស្រាយទៅបាន មានឈ្មោះហើយ ប៉ុន្តែមានគេយកឈ្មោះហ្នឹងទៅបោះឆ្នោតបានមុន ដូច្នេះអ្នកមានឈ្មោះមិនទាន់បានផ្តិតមេដៃហ្នឹង ក៏មិនបានបោះឆ្នោត ដូច្នេះនេះ ជាបញ្ហា ប៉ុន្តែតិចតួចទេ ដែលយើងអាចនឹងដោះស្រាយបាននៅពេលណាដែរបញ្ជីឈ្មោះរបស់យើង យើងធ្វើបច្ចុប្បន្នភាពទៅឃើញថាកាន់តែសុក្រឹត្យ ពីមួយឆ្នាំទៅមួយឆ្នាំ ។

ទី១៥. បញ្ហាខុសនីតិវិធី ហើយគួរតែពិនិត្យដែរ គឺអាជ្ញាធរនៅថ្នាក់ភូមិឃុំសំរួលអ្នកក្រៅពី ភូមិឃុំហ្នឹងមកចុះឈ្មោះនៅឯក្នុងភូមិឃុំ ខេត្តឯទៀតៗ ក៏បានលើកបញ្ហានេះដែរ ដូច្នេះយើងគួរតែពិនិត្យមើល ជៀសវាងកុំឱ្យមានបញ្ហានេះតទៅទៀត ។

ទី១៦. យើងគិតថាបញ្ហានេះ ជាបញ្ហាតូចតាច ប៉ុន្តែខ្ញុំបាទគិតថាអាចមានឥទ្ធិពលនាំឱ្យមានការមិនសប្បាយចិត្តទៅដល់អ្នកបោះឆ្នោត គឺធ្វើយ៉ាងណាដើម្បីឱ្យ ការិយាល័យបោះឆ្នោតនីមួយៗ ដែលនៅក្រោមការគ្រប់គ្រងរបស់ PEC និង CEC គឺសុំធ្វើយ៉ាងណាឱ្យមានរបៀបរៀបរយនៅក្នុងពេលដែលតំរង់ជួរ បោះឆ្នោត ហើយឱ្យបោះឆ្នោតបាន ជាពិសេសពីរម៉ោង មុនពេល ឬក្រោយពេលបើកទ្វារ ព្រោះខ្ញុំបាទដើរសង្កេតការណ៍មើលនៅ ការិយាល័យបោះឆ្នោត គឺមានតែពីរបីម៉ោងមុនហ្នឹងទេ ដែលមានគំហុកខ្លាំងមែនទែន ។ អស់ហើយតែដល់ម៉ោង១២ គឺសឹងតែគ្មានអ្នកទៅ បោះទៀតទេ ដូច្នេះយើង ត្រៀមលក្ខណៈយ៉ាងម៉េចក្នុងពីរ ឬបីម៉ោងមុនហ្នឹង ឱ្យមានរបៀបរៀបរយទៅ ហើយនៅក្នុងនេះខាងយន្តការ ខប់សែល នៅថ្នាក់ជាតិ ក៏បានកំពុងតែ សិក្សាជាមួយខាង គជប ដើម្បីធ្វើយ៉ាងណា សុំកំលាំងស្ម័គ្រចិត្តអំពីនិស្សិតសាកលវិទ្យាល័យ ដែលគាត់អាចមានឆន្ទៈ មកជួយនៅក្នុងថ្ងៃបោះឆ្នោតនោះបាន ហើយការស្ម័គ្រចិត្តទៅទៀតដោយមិនចាំបាច់អស់លុយ អស់កាក់ទេ គ្រាន់តែនំប៉័ង ឬមួយក៏ថ្លៃបាយបន្តិចបន្តួចហ្នឹង ហើយខាង គជប គាត់កំពុងតែសិក្សាដែរចំពោះករណីនេះ ដូចលោកប្រធាន PEC បានមានប្រសាសន៍ហើយ មន្ត្រីការិយាល័យមានតែ ៥នាក់ បើចែក ម្នាក់ឱ្យទៅជួយក្នុងរឿងហ្នឹងទៀត គឺពិបាកណាស់ ដូច្នេះយើងអាចយក

កំលាំងនិស្សិតមកជួយដែរ ។ នៅក្នុងការរៀបចំរាំទិការនៅតាមខេត្ត នានា គាត់ធ្វើការបាន ហើយមានប្រសិទ្ធភាពណាស់ ហើយឯករាជ្យទៀត មិនប្រកាន់ខាងណាទេ ។

ទី១៧. នៅខេត្តឯទៀត១ក៏បានលើកដែរ គឺខាងភ្នាក់ងារគណបក្ស អ្នកសង្កេតការ រួមទាំងមន្ត្រីនៅថ្នាក់មូលដ្ឋានខ្លះ បើសិនជាបានទទួលការបំពាក់បំប៉នផ្នែកបច្ចេកទេសពីខាង PEC និង CEC ឱ្យបានរៀបរយក្នុងការ អនុវត្តក្រឹត្យក្រមនីតិវិធីច្បាប់ទំលាប់ ហើយនិងក្រមសីលធមិ នេះជាការជួយឱ្យ យន្តការបង្ការទំនាស់ មានប្រសិទ្ធភាពនៅថ្នាក់មូលដ្ឋាន ។

ទី១៨. គឺសុំឱ្យមានការលើកស្ទួយស្ត្រីនៅក្នុងរចនាសម្ព័ន គឺតាំងពី NEC, PEC, CEC នេះគឺខាង គជប នៅទទួលស្គាល់ថា មានការខ្វះខាតមែន ប៉ុន្តែខេត្តកណ្តាលប្រធាន PEC បានធានាហើយថា យើងមានការបង្កើត ដូចជាមានសមាជិកស្ត្រីនៅក្នុង PEC, CEC ច្រើនជាងខេត្តឯទៀត១ ច្រើនណាស់ ដូច្នេះនេះជាមោទនភាពមួយរបស់ខេត្តកណ្តាលផងដែរ ។

ព្រះតេជគុណមុនហ្នឹងព្រះអង្គនិមន្តទៅ ព្រះអង្គបានសរសេរ មកជំរាបថា សូមជំរាបសួរដូចខាងក្រោម នៅក្នុងរដ្ឋធម្មនុញ្ញ ចែងថាប្រជាពលរដ្ឋខ្មែរទាំងពីរភេទមានសិទ្ធិបោះឆ្នោតដូចគ្នា ប៉ុន្តែចំពោះព្រះសង្ឃវិញមានសិទ្ធិដែរឬទេ ? បើមានសិទ្ធិហេតុអ្វីបានជាមានការរារាំងពីអាជ្ញាធរ ។ តាមគំនិតរបស់អាត្មាគួរណាស់តែសំរួលរឿងវិសោធនកម្មច្បាប់យ៉ាងណា ដើម្បីឱ្យមានភាពងាយស្រួល ម្យ៉ាងសំនូមពរឱ្យព្រះសង្ឃទាំងអស់ក្នុងព្រះរាជាណាចក្រកម្ពុជា មេត្តានៅជាអព្យាក្រឹត្យចុះ គឺជាការល្អបំផុត ដើម្បីកុំឱ្យមាន ការប៉ះពាល់ទឹកចិត្តរបស់ពុទ្ធិបរិស័ទគ្រប់១គ្នាទាំងអស់ ។ កន្លែងនេះរដ្ឋធម្មនុញ្ញចែងច្បាស់ ព្រះសង្ឃក៏ដូចជាប្រជាពលរដ្ឋអាចមានសិទ្ធិបោះឆ្នោតគ្រប់១គ្នា ច្បាប់ គឺច្បាស់តែម្តង ក៏ប៉ុន្តែដែលមិនច្បាស់នោះ នៅពេលដែលគណៈសង្ឃលោកចេញដីការមួយនោះ ដែលមិនមែនជាច្បាប់ទេ ព្រោះបើជាច្បាប់ គឺប្រឆាំងរដ្ឋធម្មនុញ្ញ ហើយប៉ុន្តែជាទំរង់បទណែនាំព្រះសង្ឃ គួរតែមិនទៅបោះ ដែលនាំឱ្យមានការពិភាក្សាគ្នាប្រទាំងប្រទើសក្នុងរឿងនេះ នៅពេលណាដែលរដ្ឋធម្មនុញ្ញចែងអញ្ចឹងហើយ យើងអត់មានទៅបកស្រាយឱ្យខុសពីហ្នឹងបានទេ តែបកស្រាយខុសពីហ្នឹង គឺខុសច្បាប់ដែរ ជាច្បាប់គោលធំបំផុតរបស់ព្រះរាជាណាចក្រកម្ពុជា គឺរដ្ឋធម្មនុញ្ញនេះឯង ។ លោកគិតថាចំនុចនេះ គួរតែទុកលទ្ធភាពឱ្យព្រះអង្គគ្រប់១អង្គ លោកធ្វើការសំរេចចិត្តទៅតាមស្មារតីរដ្ឋធម្មនុញ្ញ មិនគួរមានការហាមឃាត់ទេ ហើយលោកគិតថារាជរដ្ឋាភិបាល ក៏ដូចជាអាជ្ញាធរ ក៏ដូចជាគ្មានការរារាំង ឬ មួយក៏មិនឱ្យព្រះសង្ឃលោក ទៅចូលរួមបោះឆ្នោតដែរ តាមមើលទៅ ហើយវត្តមានរបស់តេជគុណទាំងអស់ គឺជាការអនុវត្តការប្រើប្រាស់សិទ្ធិរបស់ព្រះសង្ឃ ដែលចែងដោយរដ្ឋធម្មនុញ្ញ ច្បាស់លាស់ក្នុងការចូលរួមស្តាប់កិច្ចការរឿងនយោបាយ កិច្ចការរឿងសង្គមជាដើម ដូច្នេះហើយយើងអនុវត្តតែស្មារតីរដ្ឋធម្មនុញ្ញទៅបានហើយ មិនបាច់ឱ្យលើសពីនេះទេ ។